# កម្ពុជសុរិយា

ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ បោះពុម្ពផ្សាយ
អំពីពុទ្ធសាសនបណ្ឌិត្យ

បណ្ណាធិការ ផ្នែកអក្សរសាស្ត្រ: ហ្លួងនិពន្ធមន្ត្រី ញ៉ុក-ថែម, បណ្ឌិត នៅ
ពុទ្ធសាសនបណ្ឌិត្យ

បណ្ណាធិការ ផ្នែកដំណឹងសាសនា: ព្រះគ្រូបញ្ញាលិក្ខិត កៅ-ស៊ុម អ្នកត្រួតត្រា
សិស្ស នៅសាលាបាលីជាន់ខ្ពស់

## បញ្ជីរឿង


*ផ្នែកអក្សរសាស្ត្រ* — ទំព័រ

ហ្លួងនិពន្ធមន្ត្រី ញ៉ុក-ថែម . . ប្រវត្តិសាស្ត្រប្រទេសចិន "ពាក្យផ្ដើម" . . . ១១៣

ឃុនឧត្តមប្រីជា ជាប-ពិន . . អធិប្បាយសុភាសិត . . . . . . . . . . ១២៦

ឃុនបញ្ញាសោភ័ន គាំ-ឌុម . . ព័ត៌មាន ថ្លែងសេចក្ដីកាលទៅដឹកនាំយកពុទ្ធរូបនិងបល្ល័ង្ក នៅឃុំអង្គរបូរី ស្រុកព្រៃកប្បាស (តនឹងចប់) . . . . . . . . . ១៣៨

*ផ្នែកសាសនា*

លោកគ្រូអាចារ្យ ប៉ាង-ខាត់ . អរិយសច្ចជាពុទ្ធភាសិត (តមក) . . . . . ១៤៦

ហ្លួងនិពន្ធមន្ត្រី ញ៉ុក-ថែម . . ឯកញ្ញតនៃមិលិន្ទបញ្ហា (តមក) . . . . . ១៦៦


ឆ្នាំទី ១៧ — លេខ ៣ ខែម៉ាស្ស ១៩៤៥ — ដំឡៃជាវ: ១ ឆ្នាំ ១៥ រៀល

# ពាក្យដើម

រឿងប្រវត្តិសាស្ត្រប្រទេសចិននេះ យើងបានផ្តើមចុះផ្សាយសេចក្តីខាងដើមមកខ្លះហើយក្នុងទស្សនាវដ្តីកម្ពុជសុរិយាឆ្នាំ ១៩៤០ តែមានហេតុពាស់ប្រការខ្លះ នាំឲ្យយើងត្រូវខានមិនបានចុះផ្សាយហូតមកជាវេលាយូរឆ្នាំ ។ ឥឡូវប្រទេសខ្មែរបានទទួលឥស្សរភាពជាប្រទេសឯករាជ្យ ដោយកំឡាំងកងទ័ពនៃមហានគរជប៉ុន ហេតុនេះទើបកិច្ចការទាំងឡាយក្នុងស្រុក ក៏ត្រូវតែប្រែប្រួលជាថ្មីខ្លះ ដើម្បីតម្រូវទៅតាមកាលសម័យនៃនយោបាយរបស់មហាអាស៊ីបូព៌ាទិស ដែលមានមហានគរជប៉ុនជាប្រមុខ ទុកដូចជាអ្នកនាំប្រជាជាតិផ្សេងៗ នៅអាស៊ីទូទាំងកើតទៅកាន់សេចក្តីចំរើនរុងរឿងបែបថ្មី ។

ហេតុដូច្នេះ ទស្សនាវដ្តី កម្ពុជសុរិយាតាំងពីលេខ ៣-៤-៥ ។ល។ ឆ្នាំ ១៩៤៥ ទៅ ត្រូវតែមានការប្រែប្រួលខ្លះ គឺយើងត្រូវប្រមូលយករឿងល្អៗ ដែលជាប្រយោជន៍ដល់ខេមរជាតិទាំងខាងគតិលោក ទាំងខាងគតិធម៌ សម្រាប់ចុះផ្សាយក្នុងទស្សនាវដ្តីនេះរាល់ៗខែរៀងទៅ ។ តែគួរឲ្យទឹកស្តាយពន់ពេក ចំពោះសន្តានចិត្តរបស់ជាតិយើង ច្រើនតែមិនសូវយកចិត្តទុកដាក់សិក្សារៀនសូត្រអារ្យធម៌ - វប្បធម៌ - អក្សរ-សាស្ត្ររបស់ជាតិខ្លួនឡើយ បណ្តោយឲ្យរលាយសាបសូន្យអស់ទៅជាច្រើនៗ នៅវេលាដែលប្រទេសខ្មែរនៅក្រោមអំណាចបារាំងសែសនោះ

អក្សរសាស្ត្រខ្មែរបានសាបសូន្យទៅជាច្រើន គួរឲ្យទឹកស្ដាយណាស់ ដល់មកសម័យឥឡូវនេះ យើងត្រូវតែផ្លាស់នយោបាយថ្មី ដើម្បីជួយជ្រោមជ្រែងអក្សរសាស្ត្រនិងសិល្បការរបស់ជាតិឲ្យបានចំរើនឡើងវិញ គឺត្រូវប្រកាន់ថា ភាសាខ្មែរជាភាសាប្រសើរបំផុត សម្រាប់ជាតិខ្មែរ អក្សរសាស្ត្រខ្មែរជារបស់ល្អបំផុត សម្រាប់ជាតិខ្មែរ ។ ខ្មែរត្រូវប្រើនិយាយតែភាសារបស់ជាតិខ្លួន ខ្មែរត្រូវសរសេរតែអក្សររបស់ជាតិខ្លួន ក្នុងការនិយាយឬសរសេរ បំពុំត្រូវទៅរកបងប្អូនរួមជាតិជាមួយគ្នា នេះជាឧបាយរក្សាជាតិឲ្យបានគង់ទ្រង់ ១ ផ្លូវដែរ

សេចក្ដីខាងលើនេះ យើងមិនត្រូវនាំយកមកនិយាយក្នុងទីនេះទេ ព្រោះសេចក្ដីខាងមុខជាពាក្យផ្ដើមអំពីប្រវត្តិសាស្ត្រចិន គួរតែសរសើរចំពោះរឿងពង្សាវតាររបស់ចិន ។ ឯប្រវត្តិសាស្ត្រខាងដើមរបស់ចិននេះ យើងបានដកស្រង់យកមកអធិប្បាយដោយសង្ខេប ៗ ងាយយល់ងាយស្ដាប់ ដើម្បីជាគ្រឿងប្រដាប់សតិបញ្ញារបស់ខេមរជាតិក្នុងកម្ពុជរដ្ឋនេះ ។ ក្រៅអំពីនេះ យើងនឹងព្យាយាមប្រមូលយកក្បួនសាស្ត្រ និងប្រវត្តិសាស្ត្ររបស់នានាជាតិ រៀបរៀងជូនដល់ខេមរជាតិយើងនេះ សម្រាប់ចុះផ្សាយក្នុងទស្សនាវដ្ដី កម្ពុជសុរិយានេះជាលំដាប់តទៅ ។

បណ្ណាធិការ

# ប្រវត្តិសាស្ត្រប្រទេសចិន

## ភាគទី ១

## វគ្គទី ១

# អំពីជាតិកំណើតចិន

ដែនដីដែលចិនតាំងនៅក្នុងសព្វថ្ងៃនេះ មិនមែនភូមិប្រទេសដើមរបស់ចិនទេ គឺជាដែនដីដែលចិនបានមកដោយការច្បាំងតស៊ូ ជាយូរអង្វែងនឹងម្ចាស់ស្រុកដាន់ដើម ដោយវៃរុកកន្ទ្រានយកបន្តិចម្តងៗ ត្រាតែបានជាសម្បត្តិរបស់ចិនយ៉ាងខ្ជាប់ខ្ជួនរហូតមក ។ ចុះដើមកំណើតជាតិចិននៅទីតំបន់ណា? ប្រស្នានេះអ្នកប្រាជ្ញតាំងឡាយខាងប្រវត្តិសាស្ត្រ នៅជជែកប្រកែកគ្នាមិនទាន់ដាច់ស្រេច គឺខ្លះនិយាយថា ពួកចិនចេញមកពីស៊ីបេរី ខ្លះថាមកពី អ៊ីរ៉ង់ ខ្លះថាមកពីមេសូប៉ូតាមី ជាពូជជាតិស៊ែលដេ ។ តែដែលពោលត្រូវគ្នាដោយច្រើននោះ ថាពួកជាតិចិនចេញមកពីទន្លេសាបកាស្ពៃយ៉ែន ឫសគល់កំណើតដើមរបស់ចិននៅភាគតំបន់ទន្លេសាបកាស្ពៃយ៉ែននេះ ប្រហែលក្នុងឆ្នាំ ៣៩០០ មុនពុទ្ធសករាជ (២៤៤៣ ឆ្នាំមុនគ្រិស្តសករាជ) ។ ពួកចិនបាននាំគ្នាលើកចេញមកពីទន្លេសាបកាស្ព-ៃយ៉ែន ចូលមកតាំងនៅក្នុងតំបន់ ក័ប-តារី ហើយលើកចេញពី ក័ប-តារី មកតាំងនៅក្នុងដែនដីដែលហៅថា ប្រទេសចិនសព្វថ្ងៃនេះ ។ ឯស្រុកដែលចិនចូលទៅតាំងទីលំនៅជាឡាក់ហាន ក្នុងគ្រាដំបូងនោះ នេយល់

ថាជាស្រុកចាន់-ស៊ុនឹងប៉េចិលី  តមកទើបពង្រីកអាណាខេត្តចេញទៅដល់ហេន-ស៊ី, ហ៊ូ-ណាន នឹងប័ន-ទុង  ដែលតាំងនៅទិសខាងជើង នៃទន្លេហ្វាង-ហូ  ហើយទើបផ្លូវទន្លេហ្វាង-ហូបួលមកតាំងនៅចន្លោះទន្លេហ្វាងហូ  នឹងយ៉ាង-សេ  ត្រង់តំបន់នេះហើយ ដែលជាទីមានដីជាតិល្អណាស់ ។

តាមទំនងនោះ ដែនដីទាំងឡាយដែលចិនលើកមក តាំងនៅថ្មីនេះ មិនមែនជាទីឥតមនុស្សនៅទេ  សឹងតែមានមនុស្សជាតិផ្សេងៗ នៅមកមុនហើយគ្រប់ៗតំបន់  ហើយបានមកតាំងនៅមុនចិនជាច្រើនឆ្នាំ ជាម្ចាស់ភូមិប្រទេសគេសព្វនោះ ។ ឯពួកមនុស្សជាម្ចាស់ដែនដី ដែលពួកចិនរុកចូលមកនោះ គឺពួកជាតិទីបេតាំង  កាលបើត្រូវពួកចិនបៀតបៀន ក៏នាំគ្នាថយទៅទិសខាងត្បូង  ហើយក្លាយទៅជាជាតិឥណ្ឌូស៊ីន,  មន, ខ្មែរ, ភូមា, ភូឡា, ថៃ, យួន ។

ឯដែនដីនៅទិសខាងលិចឆៀងខាងជើងនោះ ជាន់ដើមមានពួកជាតិស៊ីងតាំងនៅមុន  ជនពួកនេះជាពួកអ្នកចម្បាំងកាន់លំពែងនឹងធ្នូ  ដែលជាអាវុធសំខាន់ក្នុងសម័យបុរាណ  ដែនដីចំណែកនេះជាទីតាំងនៃស្រុកហេន-ស៊ី  កាលដែលពួកចិនដណ្ដើមយកស្រុកហេន-ស៊ីទៅបាន  ពួកស៊ីងក៏ក្លាយទៅជាសត្រូវយ៉ាងសំខាន់របស់ចិន  លុះដល់មកក្នុងឆ្នាំមុនពុទ្ធសករាជ ២២៧ ពួកស៊ីងក៏ចាប់តាំងប្រទុស្តរាយពួកចិន  ទាល់តែចិន

ទ្រាំមិនបានតោកផ្លាស់ទីក្រុងចេញពីស្រុកចេន - ស៊ី មកតាំងក្រុងនៅស្រុកហូ - ណាន់ ។ ចំណែកឯផែនដីដែលមានដីជាតិល្អ នៅត្រង់ចន្លោះកណ្តាលនៃទន្លេ ២ ហើយមានស្រុកដ៏ស្តុកស្តម្ភហៅថា ហូ - ប៉េនោះ ពីដើមមកជាស្រុករបស់ជាតិចេង - ថៃ ។ កាលពួកចិនរុករានទន្ទ្រានចូលមកដល់តំបន់នេះហើយ ពួកចេង ថៃក៏ថយទៅខាងទន្លេយ៉ាំង - សេ ទីង ខាងខែត្រហេនហូ - ណាន់បានតាំងនៅក្នុងដែនដីអស់នេះ ហើយតមកជាច្រើនឆ្នាំ ទើបរុះមកតាំងនៅក្នុងខែត្រដែលយុន - ណាន់ហៅថា អាណាចក្រពាន់ - ចៅ ។ ឯដែនដីតង់កឹងក្នុងសម័យដែលពួកចិនរុករានទន្ទ្រានមកនោះ ជាដំដើមជាដែនដីរបស់ជាតិយួន ។. ជាម្ចាស់ស្រុកលើ "ដែនដីចំណែកនេះ រហូតដល់ពុទ្ធសករាជ ៤៣២ ។

ពួកចិនដែលចូលរុករុលយកដែនដីនេះ ពេញទៅដោយចម្បាំង រាំងដល់កាប់សម្លាប់គ្នាយ៉ាងសំបើម ហើយទន្ទ្រានចូលមកបានយ៉ាងយឺតៗ មានអ្នកប្រាជ្ញប្រវត្តិសាស្ត្រគិតប្រមាណថា តាំងអំពីចិនលើកចេញអំពីកំប - តាវ មកតាំងនៅក្នុងដែនហាន់ - ស៊ី ជារយៈវេលា ៦០០ ឆ្នាំ ទើបតាំងនៅខ្ជាប់ខ្ជួនក្នុងដែនហាន់ - ស៊ី កាលប្រមាណមុនព្រះពុទ្ធសករាជ ១៨០០ ឆ្នាំ រួចមកតាំងនៅក្នុងដែនហ៊ូ - ណាន់ រវាងមុនព្រះពុទ្ធសករាជ ១៧០០ ឆ្នាំ ប្រមាណ ៥០ ឆ្នាំតមកទៀត ទើបចិនមានអំណាចរាយរាត់កាណាខេត្តបាកស្រុកផ្សេងៗ នៅទិសខាងត្បូងទន្លេលឿង (គឺ

ទេនហ្វាង - ហូ ) ។ សករាជអស់នេះគ្រាន់តែជាការប្រមាណ បើតាប់តាំងពីចិនលើកទៅតាំងនៅសាំងហាយ កាលមុនព្រះពុទ្ធសករាជ ៥៧៤ ហើយតមកទៀតប្រហែល ៤០០ ឆ្នាំ គឺក្នុងរវាងពុទ្ធសករាជ ១៧០ ហើយធ្ងឹទខ្ទៃយ៉ាំងសេទៅបានរហូតដល់ពុទ្ធសករាជ ៣០០ ឆ្នាំ ទើបចិនលុកលុយទន្ទ្រានយកបានរហូតដែនដីដែលហៅថា ប្រទេសចិនសព្វថ្ងៃនេះ ។

ក្នុងរយៈវេលាដែលកន្លងមកនេះ មានមនុស្សសំខាន់ ៗ ដែលមានឈ្មោះប្រាកដក្នុងពង្សាវតារ គឺ ហ្វ៊ូ-អ៊ី ជាអ្នកគិតបង្កើតអក្សរចិនឡើង ចិន-នុង ជាអ្នកគិតធ្វើយានមានកង់ឡើង ហ៊ាង-ទី ជាអ្នកសាងតម្រាគាពសាស្ត្រឡើង ហើយមានមហាក្សត្រដែលមានរិទ្ធិអំណាច ៣ ព្រះអង្គព្រះនាមយៅ, ស៊ុន, យូ ដែលគួរទុកជាមហាក្សត្រ ៣ ព្រះអង្គដំបូងក្នុងពង្សាវតារចិន ។

## ស្រុកចិនកើតអ្នកប្រាជ្ញសីលធម៌

ក្នុងសម័យដែលប្រទេសចិន កើតអ្នកប្រាជ្ញខាងសីលធម៌នោះ របៀបគ្រប់គ្រងស្រុកទេស ជារបៀបស្តេចត្រាញ់គ្រប់គ្រងនគរតូច ៗ ដាច់ដោយឡែកពីគ្នា ឯព្រះមហាក្សត្រដ៏ជាធំនោះ គ្រាន់តែជាប្រមុខ ដូចជារូបអ្នកតា មិនមានអំណាចត្រួតត្រាស្រុកទេសរហូតដែនដីរបស់ព្រះអង្គបានទេ ទើបមិនមានរឿងសំខាន់ៗ កើតមកអំពីព្រះមហាក្សត្រ

ឡើយ ៗ ហេតុសំខាន់ដែលកើតឡើង គឺកើតអ្នកប្រាជ្ញខាងសីលធម៌ មានឈ្មោះថា ខុងជឺ ជាដើម ។

ពាក្យថា "ខុងជឺ, ខុងជូ, កុងសឺ ឬ កុងភូសឺ" ជាឈ្មោះអ្នកប្រាជ្ញចិនម្នាក់ជាដំបូងបំផុតដែលបានតាក់តែងរបៀបរៀបចំសីលធម៌ ខ្ញុំនានប្រែជាប្រែជាជនជាតិចិន លោកអ្នកប្រាជ្ញនេះត្រូវគេហៅថា "កុងហ្វូស៊ីយូស" ។ កើតឡើងបានអាយុ ៨ ឆ្នាំ ទើបព្រះពុទ្ធជាម្ចាស់បរិនិព្វានទៅ គឺកើតមុនព្រះពុទ្ធបរិនិព្វាន ៨ ឆ្នាំ ស្រុកកំណើតរបស់លោកជាភូមិមួយតូច ក្នុងខែត្រ ចាន់-ខុង ឬ សង់-ខុង ជាចំណុះអាណាចក្រលូ ចាប់ផ្ដើមរៀនសូត្រតាំងពីអាយុបាន ១៥ ឆ្នាំ ដល់មានអាយុ ២២ ឆ្នាំ ទើបតាំងខ្លួនជាគ្រូបាអាចារ្យទេសនាខ្លួនមហាជនរហូតដល់អាយុ ៥១ ឆ្នាំ ទើបបានទទួលនាទីជាចៅហ្វាយស្រុក រួចមកបានឡើងឋានៈសក្តិជាទី អគ្គមហា-សេនាបតី (សេនាបតីទី ១) នៃអាណាចក្រលូ ។ មានសេចក្តីដំណាលថា ខុង ជឺ បានប្រាបប្រាមពួកអាមាត្យមន្ត្រីទុច្ចរិត (ដែលធ្លាប់មានតែរឿយៗ ក្នុងពង្សាវតារចិន) ចេញអស់ជាច្រើន ៗ តមកព្រះមហាក្សត្រនៃអាណាចក្រលូ ទ្រង់ជឿស្ដាប់ពាក្យញុះញង់របស់ព្រះស្នំឯករបស់ទ្រង់ ទើបមិនយកព្រះទ័យទុកដាក់នឹងពាក្យសំដីរបស់ ខុង-ជឺ ទាំងមិនសព្វព្រះទ័យឲ្យ ខុង-ជឺ ជួយទំនុកបំរុងទ្រង់តទៅទៀតផង ទើប ខុង-ជឺ គៀសដោះខ្លួនចេញទៅយ៉ាងស្ងាត់ៗ ឯស្រុកវេតី ហើយបានចាប់

ផ្តើមសរសេរគម្រាប់គម្រាសំផែនពីលទ្ធិរបស់លោក ទុកជាកេរ្តិ៍មរតកមក រួចលោកត្រឡប់មកកាន់អាណាចក្រលូវិញ ហើយក៏និក្ខមទៅ ក្នុងជន្មាយុកំណត់ ៧៩ ឆ្នាំ ។

លទ្ធិរបស់ខុង-ជឺនេះ មានប្រជាជនជាតិចិននៅគោរពរាប់អាន តាំងពីពុរាណកាលរហូតមកដល់សព្វថ្ងៃនេះ ទើបគួរចាត់លោកអ្នកប្រាជ្ញនេះជាមហាបុរស ១ របស់ទ្វីបអាស៊ី ព្រោះលោកបានរៀបចំសីលធម៌ ទុកជារបៀបរៀបរយនឹងទៀងទាត់ល្អណាស់ ។ លទ្ធិរបស់លោកមានគោលសំខាន់សំផែនថា " បើអ្នកមិនត្រូវការឲ្យអ្នកដទៃធ្វើដល់អ្នកយ៉ាងណា កុំអ្នកធ្វើដល់គេយ៉ាងនោះ អ្នកត្រូវការឲ្យអ្នកដទៃធ្វើដល់អ្នកយ៉ាងណា អ្នកត្រូវធ្វើដល់គេយ៉ាងនោះ គប្បីស្រឡាញ់អ្នកដទៃដូចជាខ្លួនរបស់អ្នក" គោលសីលធម៌នេះ ស្តាប់មើលក៏ឃើញជាងាយ ៗ មិនមែនជាល្អិតជ្រាលជ្រៅអ្វីឡើយ ប៉ុន្តែប្រសិនបើមនុស្សលោកប្រតិបត្តិតាមគ្រប់ ៗ គ្នាហើយ ពិភពលោកនឹងប្រកបដោយសេចក្តីសុខក្សេមក្សាន្ត ជាងសព្វថ្ងៃនេះជាច្រើនយោគ ។ បើពិនិត្យមើលតាមប្រវត្តិរបស់លោក ហាក់ដូចជាលោកមិនមានលក្ខណៈជាអ្នកបង្កើតតាំងសាសនាថ្មី ដូចជាសាស្តាទាំង-ឡាយ ព្រោះគោលសីលធម៌របស់ខុងជឺ មិនមែនខុងជឺជាអ្នកបញ្ញត្តតាំងឡើង ឬគិតរកឃើញបានដោយខ្លួនឯងទេ គ្រាន់តែជាអ្នកប្រមូលក្បួនច្បាប់ទំនៀមទម្លាប់, ប្រវេណី, ដំបូន្មាន, សុភាសិតនិងគំនិតគតិគួរ

របស់អ្នកប្រាជ្ញចាស់ៗ មុនសម័យខុងជឺឡើងទៅ ហើយយកមកចងក្រងទុកជាក្បួនច្បាប់តមក ។ ខុងជឺជាអ្នកប្រាជ្ញដែលមិនពោលអាងដល់ឋានសួគ៌ឡើយ ហើយបើមានគេបានសួរលោកអំពីរឿងឋានសួគ៌លោកតបថា "សូម្បីតែរឿងរ៉ាវនៅលើផែនដី ក៏មិនទាន់ដឹងបានសព្វគ្រប់ទៅហើយ ទំនងដឹងដល់ទៅរឿងរ៉ាវក្នុងឋានសួគ៌ដូចម្ដេចបាន" ។ ប្រការមួយទៀត ខុងជឺមានលក្ខណៈវិសេសមួយយ៉ាង ខុសពីលក្ខណៈរបស់គណាចារ្យអ្នកបង្កើតលទ្ធិសាសនាទាំងឡាយ គឺខុងជឺមិនដឹងការអ្វី ក៏ពោលត្រង់ៗមកថាមិនដឹង ទាំងប្រកាន់ពាក្យសត្យប្រចាំខ្លួនលោកថា "ការអ្វីដែលដឹង, ត្រូវពោលថាដឹង, ការអ្វីដែលមិនដឹង, ត្រូវពោលថាមិនដឹង; នេះហើយដែលហៅថាជាអ្នកដឹងតាមពិត" ។ ប្រសិនបើទុកជាពាក្យប្រៀនប្រដៅរបស់ខុងជឺ មិនមានវង់ធំទូលាយដូចជាសាស្ដាឯទៀតៗ ក៏ដោយ តែអ្នកប្រាជ្ញទាំងឡាយសឹងមានយោបល់យល់ត្រូវគ្នាថា ខុងជឺជាមហាបុរសមួយរបស់ទ្វីបអាស៊ី ដោយបានរៀបចំគោលសីលធម៌យ៉ាងប្រពៃទុកឲ្យចិន ហើយបានផ្សាយចេញទៅក្រៅប្រទេសចិនផង ។

អំណើះកាលតមក ខុងជឺអនិច្ចកម្មទៅបាន ១០០ ឆ្នាំ មានអ្នកប្រាជ្ញចិនម្នាក់ កើតឡើងថ្មីហៅថា "ម៉េងស៊ុ" ដែលគួររាប់ថាជាសាវកសំខាន់មួយរបស់ខុងជឺ តែមិនទាន់បានឃើញខុងជឺទេ ព្រោះម៉េង-ស៊ុកើតក្នុងពុទ្ធសករាជ ១៧១ នៅក្នុងអាណាចក្រលូដែរ ម៉េង-ស៊ុបាន

សិក្សាលទ្ធិរបស់ខុងជឺទីងរៅខុងជឺ ហើយបានប្រកាសផ្សាយលទ្ធិនេះឲ្យកាន់តែរីកចំរើនឡើងទៀត ម៉េង-ស៊ីបានទទួលតំណែងក្នុងរាជការជាអគ្គមហាសេនាដូចជាខុងជឺដែរ ។ ឯគោលដំបូន្មានរបស់ម៉េង-ស៊ី មានទំនងខុសគ្នានឹងខុង-ជឺបន្តិច គឺម៉េង-ស៊ីយកចិត្តទុកដាក់ទូន្មានខាងគោលវិជ្ជាការផែនដីច្រើនជាងច្បាប់សីលធម៌ ។ ម៉េង-ស៊ី នេះមានអាយុយឺនជាងខុង-ជឺ ៤ ឆ្នាំ គឺមានអាយុ ៨១ ឆ្នាំទើបអនិច្ចកម្ម ។

ក្រៅអំពីលទ្ធិខុង-ជឺដែលពោលមកនេះ នៅមានលទ្ធិមួយទៀតដែលចិនមានសេចក្ដីគោរពកាន់ហូតមកដល់សព្វថ្ងៃនេះគឺលទ្ធិតៅ-អ៊ីស្ម៍ លោកអ្នកប្រាជ្ញដែលបង្កើតលទ្ធិនេះគេហៅថា ឡៅ-ស៊ឺ កើតមុនខុង-ជឺ ៥៣ ឆ្នាំ គឺមុនពុទ្ធសករាជ ៦១ ឆ្នាំ ។ លទ្ធិតៅអ៊ីស្ម៍នេះប្រកាន់ថា មានព្រះជាធំបំផុតនៅលើឋានសួគ៌ត្រូវធ្វើពិធីបន់ស្រន់បួងសួងអង្វរ ទើបព្រះជាម្ចាស់ទ្រង់ប្រោសប្រាណ តមកលទ្ធិនោះក្លាយទៅជាកប់អានខ្មោចបិសាចទេវតានិងអ្នកតា ដែលពួកចិនជាប់កប់អានតមកដល់សព្វថ្ងៃនេះ ។

នៅសម័យដែលប្រទេសចិនកំពុងសំបូរដោយអ្នកប្រាជ្ញខាងសីលធម៌ ស្រុងកេសេចក្ដីចំរើនខាងផ្លូវសតិបញ្ញា ទីងចាត់របៀបសីលធម៌ដល់ប្រជាជនជាតិចិននោះ ប្រទេសចិនបានបែកខ្ញែកទៅជាច្រើនអាណាចក្រ សឹងមានក្សត្រគ្រប់គ្រងដាច់ដោយឡែក ។ ទើបបណ្ដាលកើត

ទៅជាចម្បាំងកាំងផល់ផតស្រាក បណ្ដាអាណាចក្រតូច ៗ ក៏រលំរលាយចូលទៅក្នុងអាណាចក្រធំ ។ នៅទីបំផុតសល់ត្រឹម ២ អាណាចក្រធំ ។ ដែលមានទីក្រុងនៅឃ្លាតឆ្ងាយអំពីគ្នា អាណាចក្រ ១ ទៀតហៅថា ចិន (ជិន,ស៊ុន) តាំងទីក្រុងនៅស្រុកចេន-ស៊ុ អាណាចក្រ ១ ទៀតហៅថា ជូ (ចូ,ស៊ូ) តាំងទីក្រុងនៅហូ-ប៉ី ។ អាណាចក្រទាំង ២ នេះបានច្បាំងគ្នាអស់យូរអង្វែង នៅទីបំផុតពួកចិនមានជ័យជំនះ ព្រះមហាក្សត្រចិនទ្រង់ព្រះនាមក៊ីង-ឈិង ទ្រង់ជាព្រះរាជាធិរាជគ្រប់គ្រងមហាណាចក្រចិនទាំងមូល កាលពីពុទ្ធសករាជ ២៩៧ មានព្រះនាមថាវ៉ុង-ទី ដែលជាតំណែងប្រហែលនឹងសេសាររបស់ក្រុងរោម ។ ឯព្រះរាជវង្សរបស់ព្រះអង្គហៅថារាជវង្ស ជិនឬចិន ទីក្រុងរបស់ព្រះរាជាធិរាជព្រះអង្គនេះតាំងនៅស្រុកហៀន-ហ៊ុង នៅខាងកើតនៃស្រុកស៊ី-ង៉ាន ក្នុងនៃក្រចេន-ស៊ី ។

វ៉ុង-ទីព្រះអង្គនេះ ជាអ្នកគ្រប់គ្រងរាជអាណាចក្រជាមេទ័ព ទ្រង់បានគ្រប់គ្រងរាជអាណាចក្រចិនទាំងមូល ដែលគួរកប់ថាជាសេសារអង្គដំបូងនៃទ្វីបអាស៊ីទិសខាងកើត ។ ទ្រង់បានគ្រប់គ្រងរាជសម្បត្តិ ៣៦ ឆ្នាំ គឺតាំងពីពុទ្ធសករាជ ២៩៧ ដល់ពុទ្ធសករាជ ៣៣៣ តាមដោយពិតរាជអាណាចក្រថ្មីនេះមិនមែនជារូបភូមិប្រទេសថ្មីទេ ព្រោះតាំងពី ២៥០ ឆ្នាំមកហើយខុង-ជឺបានព្យាយាមកែប្រែទំនៀមទម្លាប់បុរាណ ហើយប្រកាស

ទូន្មានផ្សាយសីលធម៌ទុកមកជាច្រើនណាស់ហើយ ទើបធ្វើឲ្យលទ្ធិខុងជឺនៅជាប់ស្អិតក្នុងចិត្តរបស់ពួកមល្លក្សត្រ (ស្តេចត្រាញ់) និងចិត្តគំនិតរបស់ប្រជាជនទាំងឡាយ ដោយពួកបុត្របុរសបានទទួលដំបូន្មានផ្ទាល់មកអំពីខុងជឺ ហើយទទួលអប់រំតាមបែបមល្លក្សត្រមកអំពីបុរាណកាល ។ - ព្រះបាទវ៉ុង-ទីទ្រង់មិនសព្វព្រះទ័យឲ្យមានក្សត្រគ្រងនគរតូចៗតទៅទៀត ប៉ុន្តែបើទ្រង់កែប្រែវេលាណាក៏តែងតែត្រូវពួកអាមាត្យរបស់ទ្រង់ទទឹងទាស់មិនយល់ព្រមផង ដោយអាងផល់លទ្ធិរបស់ខុង-ជឺជាមហាអ្នកប្រាជ្ញរបស់ចិនជានិច្ច ។ ឯព្រះបាទវ៉ុង-ទីទ្រង់ស្អប់លទ្ធិខុងជឺនេះណាស់ ព្រោះជាហេតុជំទាស់នឹងប្រសាសនោបាយរបស់ព្រះអង្គ ហើយទ្រង់មិនសព្វព្រះទ័យឲ្យអ្នកណាមួយកាន់កាប់កាន់លទ្ធិនេះតទៅទៀត ទើបទ្រង់ឲ្យដុតបំផ្លាញក្បួនខ្នាតនឹងសៀវភៅផ្សេងៗជាច្រើន ដែលពួកអ្នកប្រាជ្ញអស់នោះបានតែងទុកមក ។ រឿងដុតបំផ្លាញក្បួនខ្នាតនេះ ជារឿងសំខាន់មួយក្នុងប្រវត្តិសាស្ត្ររបស់ចិន ព្រោះធ្វើតែប្រជាជនជាតិចិនទូទៅមានសេចក្តីតោតខ្លាចព្រះតេជានុភាពព្រះមហាក្សត្រលះបង់លើកលែងគោរពរាប់អានលទ្ធិខុង-ជឺ បែរជាទំនងនឹងព្រះមហាក្សត្រហើយនាំគ្នាកាន់តែគោរពបូជាលទ្ធិខុងជឺច្រើនឡើងទៀត ទើបនាំគ្នាបះបោរកាប់សម្លាប់គ្នារើកដល់អស់បុណ្យព្រះមហាក្សត្រនេះហើយ លទ្ធិខុងជឺត្រឡប់ចំរើនរុងរឿងឡើងវិញ ដោយព្រះមហាក្សត្រក្រោយៗមក ទ្រង់ជួយឧបត្ថម្ភដោយប្រពៃ ៗ

ក្នុងសម័យដែលពួកចិនតាំងឡាក់ឋានបានខ្ជាប់ខ្ជួន ហើយមានសេចក្តីចំរើនរុងរឿងឡើងដូច្នោះ ពួកហ្វូនឬពួកមន្ទុលក៏ចាប់ផ្តើមរុករានទន្ទ្រានទឹកដីនៃនគរសម្រាប់តាំងឡាក់ឋានខ្លះដែរ ។ កាលពីក្នុងរជ្ជសម័យព្រះបាទវ៉ុង-ទី ពួកហ្វូនដែលចិនហៅថា ហាង-នូ ឬ ហៀង-នូ នោះបានលុកលុយយកដែនដីខាងសមុទ្រជប៉ុន ព្រះបាទវ៉ុង-ទីទ្រង់ធ្វើចម្បាំងតស៊ូនឹងពួកនេះជាវេលាយូរ នៅទីបំផុតទ្រង់បានកសាងកំពែងយ៉ាងធំសម្បើមឡើង សម្រាប់ការពារស្រុកចិន កាលពីពុទ្ធសករាជ ៣២៥ ជារយៈវែងដល់ ៣.៣០០ គីឡូម៉ែត្រ គួរចាត់ជាការកសាងយ៉ាងសម្បើមបំផុត ដែលមានជាប់តរហូតមកដល់សព្វថ្ងៃនេះ ។ ឯដែនដីនៅកណ្តាលទ្វីបអាស៊ី ក៏ត្រូវពួកហ្វូនរុករានទន្ទ្រានចូលទៅ ត្រាតែពួកយូរេជីជាម្ចាស់ស្រុកភៀសខ្លួនចូលទៅក្នុងប្រទេសឥណ្ឌា ទើបតែដែនមន្ទុលក៏ធ្លាក់ទៅនៅក្រោមអំណាចពួកហ្វូនទាំងអស់ ។

(មានត)

# អធិប្បាយសុភាសិតខ្មែរ

## ឃុនឧត្តមប្រីជា ចាប-ពិន និពន្ធបណ្ឌិត

នៅពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ រៀបរៀង

១· បន្ទាមុត យកបន្ទាដោះ

២- សេះជាប់ យកសេះតាម

៣- ភ្លើងឆេះ ដុតភ្លើងតប

— ប្រទេសខ្មែរយើង តាំងពីបុរាណមក បណ្ដាជនដែលជាវោហារកោសល មានប្រតិភាណខាងផ្លូវនិយាយ, កាលបើគេនិយាយពីរឿងអ្វីដែលសេចក្ដីក្នុងរឿងមានទំនងគួរដល់សុភាសិតណា គេតែងយកសុភាសិតនោះមកបញ្ជាក់ត្រង់ចន្លោះ ៗ នោះ ៗ ដើម្បីបញ្ជាក់សេចក្ដីឲ្យច្បាស់លាស់ឲ្យងាយស្ដាប់ ៗ សុភាសិតខ្មែរ មានច្រើនបទ តែមិនបានស្រង់យកគ្រប់បទទាំងអស់មកអធិប្បាយទេ, ស្រង់យកតែ ៣ បទ ដូចបានតាំងទុកជាមាតិកាខាងដើមនេះ មកអធិប្បាយ ៗ សុភាសិត ៣ បទនេះ កាលបើមានទំនងហើយអ្នកនិយាយគេតែងដាក់ថា "បន្ទាមុត យកបន្ទាដោះ" ឬថា "សេះជាប់យកសេះតាម" ឬក៏ថា "ភ្លើងឆេះ ដុតភ្លើងតប"; ប៉ុន្តែអ្នកនិយាយខ្លះកាលគេយកតែមួយដាក់ ខ្លះកាលគេយកតែពីរ ខ្លះកាលគេយកទាំងបី ព្រោះសេចក្ដីជាមួយគ្នា ៗ

សុភាសិតទាំង៣បទនេះ មានសេចក្តីជាមួយគ្នាក៏ពិតមែន ប៉ុន្តែមានអធិប្បាយជា ២យ៉ាង គឺអធិប្បាយត្រង់ៗ១យ៉ាង អធិប្បាយប្រៀប១យ៉ាង ។

## អធិប្បាយត្រង់

១- ធម្មតាបន្លា ជារបស់មានសណ្ឋានស្រួច តែងមុតចូលទៅក្នុងសាច់មនុស្សនិងសត្វនានា, កាលបើគេដឹងថាបន្លាមុតហើយ គេតែងយកបន្លាដូចគ្នា ឬវត្ថុដែលមានមុខស្រួចដូចបន្លា មកដោះ ទើបបន្លានោះរង្គោះចេញមក, បើមិនដូច្នោះ បន្លានោះ មិនរបូតចេញមកឡើយ ។

២- ធម្មតាសេះ ជាសត្វមានល្បឿនលឿនជាងសត្វជើង ៤ ជើង ២ គ្រប់យ៉ាង, កាលបើគេដឹងថាសេះដាច់ហើយ គេតែងយកសេះដូចគ្នាជិះទៅតាម ទើបទាន់, បើមិនដូច្នោះ មិនងាយទាន់ឡើយ ។

៣- ធម្មតាភ្លើង វេលាខែប្រាំង តែងឆេះព្រៃរាលទៅក្នុងទីផ្សេងៗ អ្នកដែលមានខ្ទមឬវត្ថុអ្វីនៅក្នុងព្រៃនោះ កាលបើគេដឹងថាភ្លើងឆេះរាលតម្រង់មករកទីកន្លែងឬវត្ថុរបស់គេ គេតែងឆ្ការព្រៃជុំវិញខ្ទម ឬវត្ថុរបស់គេឲ្យរលីង ហើយគេដុតព្រៃជុំវិញទីដែលគេឆ្ការនោះ ឲ្យឆេះតបទៅរកភ្លើងព្រៃ មុនវេលាដែលភ្លើងព្រៃឆេះមកដល់ ដើម្បីបង្ការមិនឲ្យអន្តរាយ, ធ្វើបែបនេះ ទើបភ្លើងព្រៃមិនឆេះខ្ទមឬវត្ថុផ្សេងៗ; សូម្បីក្នុងវិន័យពុទ្ធសាសនា ក៏មានពុទ្ធានុញ្ញាតឲ្យភិក្ខុអ្នកនៅក្នុងព្រៃ ដុតភ្លើងតបបែបនេះបង្ការខ្លួនបាន ឥតមានទោសឡើយ ។

# អធិប្បាយប្រៀប .

បើមានហេតុកើតឡើងចំពោះបន្ទា ចំពោះសេះ ឬចំពោះក្មេងគេ កែងធ្វើ ដូចពោលមកខាងដើម, សេចក្ដីនេះយ៉ាងណា, ឧបាយដែលនឹងទូន្មានមនុស្សក៏ដូចគ្នា គឺបើមានមនុស្សទុជ្ជន មកប្រើឧបាយបោកប្រាស់ដោយសេចក្ដីវៀចវេរបែបណាមួយ គេត្រូវរកឧបាយប្រហែលគ្នា នោះទៅផ្ចាញ់ផ្ចាល់ឲ្យទល់ពិស ទើបត្រឡប់ជាត្រង់ភ្លឺងទៅតាមសេចក្ដីពិតវិញបាន ដូចរឿងនិទានដែលពោលខាងមុខនេះ:

ក្នុងកាលកន្លងរំលងទៅយូរហើយ មានស្រុក ១ ឈ្មោះ ចិត្តលិត្រាម; ក្នុងស្រុកនោះ មានអាពម ១ ឈ្មោះ អម្ពលដ្ឋិរន, មានកុដុម្ពិកម្នាក់ឈ្មោះសុចិ ជាញោមអាពម, ក្នុងអាពមនោះ មានសមណ ១ រូប ឈ្មោះ សុទត្ត ៗ ថ្ងៃ ១ សុទត្តសមណៈ មានការទៅសួរញាតិញោមឯភូមិឆ្ងាយ បានផ្ញើហិប ១ នឹងសុចិកុដុម្ពិក, ក្នុងហិបនោះ មានមាសជាច្រើនដំឡឹងនៅខាងក្រោម ឫសឈើសម្បកឈើជាថ្នាំនៅខាងលើ ៗ កាលកុដុម្ពិកយកហិបទៅទុកឯផ្ទះ បើកមើលឃើញមាស ក៏ត្រេកអរ ហើយយកទង់ដែងម៉ាន់ទម្ងន់ស្មើគ្នាមកប្ដូរយកមាសទុកជារបស់ខ្លួន ៗ លុះសុទត្តសមណៈត្រឡប់មកដល់អាពមវិញ ឲ្យសុចិកុដុម្ពិកយកហិបមក, លុះកុដុម្ពិកទៅផ្ទះផុតទៅ លោកបើកហិបមើលឃើញសុទ្ធតែទង់ដែង ក៏ដឹងច្បាស់ថាកុដុម្ពិកលួចប្ដូរ តែលោកគិតថា "បើអញសួរ

ដេញដោលគេ កាលណោគាត់នឹងទទួលថាប្ដូរ បើដូច្នេះ ចាំអញធ្វើឧបាយកលឲ្យទល់ពិសនឹងគាត់វិញ ទើបជា", ថ្ងៃក្រោយលោកឲ្យហៅកុដុម្ពិកនោះមកប្រាប់ថា "អាត្មាត្រូវការទៅសួរញាតិញោមឯភូមិឆ្ងាយទៀត ចូរញោមអនុគ្រោះឲ្យកូនប្រុសតូចរបស់ញោមជូនអាត្មាទៅ ហឹបនេះអាត្មាសុំផ្ញើនឹងញោម ។ កុដុម្ពិក៏យកហឹបទៅទុកឯផ្ទះ ដោយឥតសង្ស័យ យកកូនឲ្យទៅតាមលោក ។ ឯសុទត្តសមណៈទៅដល់ផ្ទះញាតិញោមក៏ពយដំណើរប្រាប់អស់បងប្អូនសព្វគ្រប់, ផ្ញើកូនក្មេងនោះទុកហើយឲ្យគេចាប់ស្វាក្នុងព្រៃមកបង្ហឹកឲ្យចេះមាយារបស់មនុស្ស រួចនាំមកឯអាពម, លុះដល់ហើយក៏ហៅកុដុម្ពិកមកប្រាប់ថា "កាលដែលអាត្មាយកកូនញោមទៅតាមនោះ លុះទៅដល់ក្នុងព្រៃ កូនញោមវាទៅបេះស្លឹកឈើផ្លែឈើស៊ី ក៏ស្រាប់តែមានរូបរាងខុសប្រក្រតីទៅ, នេះហើយជាកូនរបស់ញោម" ។ កុដុម្ពិក៏ជឿថា កូនរបស់ខ្លួនដូច្នោះមែន ក៏តូចចិត្តដួលសន្លប់បាត់ស្មារតី លុះដឹងខ្លួនឡើងវិញ ទើបអង្វរសុទត្តសមណៈឲ្យជួយរកគ្រូពេទ្យមកព្យាបាល ។

កាលដែលអ្នកទាំងពីរកំពុងនិយាយគ្នានោះ គ្រាវេលាដែលព្រះបាទសុរូបបរមពោធិសត្វ ទ្រង់ចេញចាកព្រះនគរដោយប្រាថ្នានឹងទៅទ្រង់ព្រះផ្នួសជាឫសីក្នុងព្រៃហិមពាន្ត ស្ដេចមកដល់អាពមនោះដែរ លុះទ្រង់បានឮសំឡេងសុបិកុដុម្ពិកយំសោកនឹងកូន ទ្រង់ចូលទៅនមស្ការ

សុទត្តសមណៈ យល់លក្ខណៈពោធិសត្វ ក៏ស្គាល់ថាជាអ្នកប្រាជ្ញ គាប់ពិភាក្សាសេចក្ដីរបស់លោកបាន លោកក៏សូមឲ្យពោធិសត្វជួយពិភាក្សា ពោធិសត្វទ្រង់សង្កេតសួរយកចម្លើយអំពីគូវិវាទទាំងពីរនាក់, កាលបានជ្រាបសេចក្ដីពិតដោយប្រាកដហើយ ក៏ទ្រង់ប្រកាសសេចក្ដីថា "បើផ្លូវត្រង់មនុស្សដើរក៏ត្រង់ ផ្លូវវៀចមនុស្សដើរក៏វៀច, បើមាសនព្វគុណក្លាយទៅជាទង់ដែង កូនក្មេងក៏ក្លាយទៅជាស្វា ព្រោះកំពើវៀចនោះឯង", ទ្រង់ប្រកាសសេចក្ដីនេះហើយ ទើបសួរកុដុម្ពិកថា "ឥឡូវយើងស្គាល់មុខមនុស្សកំណាចអន្ធពាលច្បាស់ហើយ អ្នកឯងចេះគម្ពីរមន្តឬទេ? បើចេះត្រូវស្រោចទង់ដែងឲ្យក្លាយជាមាសទៅ, យើងនឹងស្រោចស្វាឲ្យទៅជាមនុស្សវិញបាន, បើអ្នកឯងស្រោចទង់ដែងឲ្យទៅជាមាសពុំបានទេ យើងក៏ស្រោចស្វាឲ្យទៅជាមនុស្សពុំបានដែរ" ។

សុចិត្តកុដុម្ពិកបានស្ដាប់ហើយក៏វិលទៅផ្ទះ ប្រាប់ប្រពន្ធតាមដំណើរនោះ, ប្រពន្ធក៏យំសោកអាណិតកូនក្រៃពេក; កាលអ្នកទាំងពីរប្រឹក្សាគ្នាក៏ដឹងថា "ហេតុនេះ ច្បាស់ជាកើតមកពីកំពើដែលយើងលួចប្ដូរមាសសុទត្តសមណៈ, បើដូច្នេះ ត្រូវយើងយកទង់ដែងចេញ យកមាសដាក់ប្រគេនលោកវិញ, ទើបកូនយើងត្រឡប់ជាមនុស្សដូចដើម", កុដុម្ពិកក៏យកមាសដាក់ក្នុងបាត្រហើយ ក៏យកទៅប្រគេនលោក, សុទត្តសមណៈ បើកបាត្រមើលឃើញមាសរបស់លោក ជាមាសសុទ្ធដូចដើម. ទើបលោក

ពោលថា "អើហ្ន៎! មាសក្លាយជាទង់ដែងដោយអំណាចអំពើវៀច, ទង់ដែងក្លាយជាមាស ដោយអំណាចអំពើត្រង់" ។

ចំណែកបរមពោធិសត្វ ទ្រង់ពិភាក្សាសេចក្ដីនោះហើយ ទ្រង់លាសុទត្តសមណៈ ធ្វើដំណើរឆ្ពោះទៅព្រៃហិមពាន្ត ។

សុទត្តសមណៈ ក៏នាំយកស្វាទៅលែងក្នុងព្រៃ ហើយទៅឯស្រុកញាតិញោម យកកូនមកឲ្យសុបិកុដុម្ពិកវិញ ។

រឿងនេះ សមនឹងសុភាសិតដែលពោលមកខាងដើមថា "យកបន្ទាដោះបន្ទា យកសេះតាមសេះ, ដុតភ្លើង គបភ្លើង" នោះឯង គឺសុបិកុដុម្ពិកមានចិត្តវៀចលួចប្តូរមាសសុទត្តសមណៈ។ យកស្វាដែលមានសភាពស្រដៀងគ្នា ទៅដោះ ទៅតាម ទៅគប នឹងសុបិកុដុម្ពិកវិញ ឲ្យទល់ពិសគ្នា ទើបធ្វើសុបិកុដុម្ពិកឲ្យទៀងត្រង់ទៅវិញបាន ។

ការធ្វើឲ្យទល់ពិសគ្នានេះ ដូចកាលមនុស្សវៀចតាំងពីដើម ធ្វើកលវៀចដាក់គ្នាទៅវិញទៅមក ដល់ដឹងគំនិតគ្នា ត្រឡប់ជាយកគ្នាជាភ្ញៀម្រាក់ទៅវិញក៏មាន; ដូចនិទានតាទិលអាខ្វច ដែលពោលខាងមុខនេះ:

ក្នុងកាលកន្លងរំលងទៅយូរហើយ មានបុរសម្នាក់ នៅស្រុកស្រែ ជាមនុស្សខ្ជិលច្រអូស មិនគិតប្រឹងរកស៊ីធ្វើការដូចអ្នកទាំងពួងឡើយ អ្នកស្រុកគេហៅថា "អាខ្វច" អានោះវាបេះតែអង្គុយត្រគោមក្បាល ផ្គន់គំនិតរកទុកចាយទាំងហុតប្រាសអ្នកស្រុក; វេលាមួយ វាយកកាំបិតស្នា

កំបុកតូច ១ ដាក់ក្នុងស្រោមជាវដីវែង ហើយកាន់ស្ពាយដើរចុះមកឯស្រុក កំពង់ក្របួរអើកាន់ទន្ទឹងអ្នកដែលគោត ៗ ។

ក្នុងវេលាជំណាលគ្នានោះ មានបុរសម្នាក់ទៀត នៅស្រុកកំពង់ មាត្រតូចតាបកន្ទិល ខុសខាត អ្នកផងគេហៅថា "តាខិល" ជាមនុស្ស កម្ជិល គិតរកតែឧបាយឆបោកអ្នកស្រុក ដូចគ្នានឹងតាខុប, តានោះកាន់ យកពាង ២ ដាក់ដីខ្សាច់ពេញ ៗ ហើយយកប្រហុក ១ ខ្ទប់ មកលាយ បន្តិច ៗ ពីលើមាត់ពាងនេះ បិទមាត់ជិតហើយរែកចេញពីស្រុកកំពង់ ឡើងទៅឯស្រុកស្រែលើ ដើររកឧបាយបោកបញ្ឆោតប្ដូរអើកាន់ទន្ទឹងអ្នក ស្រុកដូចគ្នា ។

លុះអ្នកទាំងពីរនោះ ដើរមកដល់ពាក់កណ្ដាលផ្លូវ ប្រទះគ្នាក៏សុំប្ដូរ របស់គ្នាទៅវិញទៅមក, ចំណែកតាខុប ដែលយកកាំបិតស្នាក់កំបុកបន្ទុំ ធ្វើជាវ កាលបើឃើញពាងក៏នឹកស្មានថា ប្រហុកពេញ ៗ ដល់មាត់ពាង មែន ត្រេកអរណាស់ ដោយគិតថា កាំបិតអញកំបុកតូចខ្ទីសោះ ហើយមកបានប្រហុក ២ ពាងពេញ ៗ យ៉ាងនេះ ជាលាភប្រសើរណាស់". ឯតាខិលដែលយកប្រហុក ១ ខ្ទប់បិទពីលើមាត់ពាងដីខ្សាច់នោះ កាល បើឃើញស្រោមជាវវែង ក៏សំគាល់ថាជាដាវមែនៗ នឹកអរណាស់ គិត ថា "ប្រហុកអញតែ ១ ខ្ទប់សោះ ហើយមកបានដាវវែងល្វៃបែបនេះ ជាភ័ព្វធំណាស់ តាំងពីអញកើតមកមិនដែលបានប្រទះលាភបែបនេះទេ"

អ្នកទាំងពីរគឺប្ដូររបស់ទៅវិញទៅមក, តែជូនទឹងប្រុសខ្លួនតែហាមគ្នាថា "កុំអាលបើកមាត់ពាង - ហូកដាមើលក្លាម", ជួរ៉ាស្រែចហើយ ក៏ញញឹមញញែម ញាក់មុខញាក់មាត់ដាក់គ្នា លាគ្នាចេញទៅតាមផ្លូវរៀងខ្លួន, លុះទៅដល់ពាក់កណ្ដាលផ្លូវអាខ្វិលដកដាមើលឃើញគាំបិតសាក់បុកគួបខ្ញី ក៏គិតថា "ឃើ! គាត់នេះ មានឧបាយមុំទអញដែរតើ" ក៏ដើរត្រឡប់មករកអាខ្វក់វិញ ដោយគិតថា "ទឹងយកគ្នាជាក្មេ" ចំណែកអាខ្វក់ហែកកញ្ចប់មាត់ពាងមើល ឃើញប្រហុកលាប១ ពីលើមាត់ពាង ខាងក្រោមសុទ្ធតែជីខ្សាច់ ក៏គិតថា "អើហ្ន៎! អញស្មានថា ក្នុងស្រុកនេះមានតែអញមួយទេ ដែលមានឧបាយបែបនេះ ឥឡូវនេះ មានគេដូចរញដែរ" ក៏ត្រឡប់មករកអាខ្វិលវិញ ដោយគិតថា "ទឹងយកគ្នាជាក្មេ" ដូចគ្នា ។ ដល់អ្នកទាំងពីរមកជួបគ្នានៅទី ១ ក៏សើចកាច់កាច់ស្រេងរកគ្នា ហើយយកគ្នាជាមិត្តរកស៊ីចិញ្ចឹមជីវិតដោយផ្លូវឆបោកបញ្ឆោតអ្នកស្រុកតទៅ ។

អាខ្វិល អាខ្វក់ ប្រើឧបាយខិលខូចតបគ្នាទៅវិញទៅមក ទល់តែសគាយក្នុងគ្នាជាក្មេដូចពោលមកហើយ, រឿងនេះ ដូចជាសមទឹងសុភាសិតដែលពោលមកខាងដើមនោះដែរ, ប៉ុន្តែតាមគោលសេចក្ដីពិតក្នុងសុភាសិតនោះ ដែលអ្នកប្រាជ្ញបុរាណលោកចង់ចុតមក ប្រហែលជាសំដៅដល់ការប្រើឧបាយក្នុងផ្លូវល្អ ដែលជាឧបាយទូន្មានមនុស្សខូច ឲ្យទៅជា

មនុស្សជាដូចជាសុខគ្គសមណៈ ប្រែខបាយផ្ញាផ្លាល់ ឲ្យខលពិសនឹង អំពើវៀចរបស់សុចិកុដ្ឋិក ធ្វើសុចិកុដ្ឋិកឲ្យជាមនុស្សទៀងត្រង់លែងមានពុតត្បុតនោះឯង ។

សេចក្តីទាំងឡាយដែលអធិប្បាយមកពីខាងលើនេះ សុទ្ធតែជាគតិលោកទាំងអស់, បើជាគតិធម៌វិញ ត្រង់សុភាសិតថា "បន្ទាមុត យកបន្ទាដោះ" នោះមានអធិប្បាយថា : បើមនុស្សណា មានសេចក្តីស្រើងថា ខ្លួនមានរូបល្អឆើតលើសគេ ឥតមានអ្នកណាល្អដូច ហើយប្រកាន់តាមហេតុនោះ រលំតែនឹងការថែទាំរូបនោះពេក ឥតគិតដល់ការមិនទៀង ជាទុក្ខ ជាអនត្តាសោះ, បើដូច្នោះត្រូវយកមនុស្សដែលមានរូបល្អជាង មកផ្ចាញ់ ទើបលះសេចក្តីស្រើងនោះបានខ្លះ ; ដូចកាលព្រះសម្មាសម្ពុទ្ធទ្រង់ទូន្មាននាងរូបនន្ទាថេរី ដែលកាលៈនៅគ្រហស្ថ គេហៅថា "នាងជនបទកល្យាណី" ជាស្រី ល្អឆើត ជាងគេក្នុងជនបទ, ដល់នាងបួសជាសមណី ក៏នៅតែមានសេចក្តីស្រើងរូប មិនទំប្រព្រឹត្តសមណធម៌, វេលាមួយនាងបានទៅស្តាប់ធម៌ទេសនា ដោយសារភិក្ខុនីឯទៀតនាំទៅ, ទៅហើយមិនហ៊ានអង្គុយចំពីមុខព្រះភក្ត្រព្រះអង្គទេ ខ្លាចព្រះអង្គសំដែងធម៌ផ្ញាផ្លាល់រូប អង្គុយពីខាងក្រោយបំបាំង ១ នឹងគេ ប្រុងស្តាប់ធម៌, ព្រះសម្មាសម្ពុទ្ធទ្រង់ជ្រាបហេតុនោះ ទ្រង់គិតថា "ថ្ងៃនេះ នាងរូបនន្ទាមកស្តាប់ធម៌ហើយ គួរតថាគតយកធម៌ដែលប្រៀប

ដូចយកបន្លាដោះបន្លា មកសំដែងឲ្យនាងស្តាប់" ហើយទ្រង់និម្មិតជាស្ត្រីមានរូបល្អលើសជាងនាងនោះទៀត ឲ្យអង្គុយបក់ផ្លិតថ្វាយ នាងរូបនន្ទាឃើញរូបនិម្មិតនោះ ល្អដូចកូនហង្ស មើលមកខ្លួនឯងឃើញអាក្រក់ដូចមេក្អែក ក៏គិតថា "យើអើ! មានគេល្អជាងអញផងហ្ន៎" ព្រះអង្គទ្រង់សំដែងព្រះត្រៃលក្ខណ៍ផង ទ្រង់ផ្លាស់រូបនិម្មិតនោះ ឲ្យឃើញជាចាស់បន្តិចម្តងៗ ផង, មិនយូរប៉ុន្មាន ក៏ទ្រង់ធ្វើឲ្យរូបនិម្មិតនោះ ដួលស្លាប់មានដង្កូវពុះត្រែតត្រាតក្នុងទីនោះ; នាងរូបនន្ទាសង្វេគខ្លាំង តាំងស្មារតីស្តាប់ធម៌ក៏បានសម្រេចមគ្គផល លះការស្រើរីរូបក្នុងខ្លួនចិត្តបាន ត្រាន់តែថែទាំដោយផ្លូវកាយតាមធម្មតាប៉ុណ្ណោះ មិនមានការជាប់ចិត្តក្នុងរូបឡើយ ។

រឿងដែលពោលមកនេះ គឺយករូបល្អ ផ្ចាញ់រូបល្អ ដូចយកបន្លាដោះបន្លា ។

មានរឿង ១ ទៀតថា: កាលព្រះសម្មាសម្ពុទ្ធគង់ព្រះជន្មនៅឡើយ មានព្រះថេរៈ ១ រូប ឈ្មោះឆន្នៈ ខាងមានះប្រកាន់ខ្លួនថា គ្រាច់បើផាន់គេ ក៏រឹងត្អឹង មិនចុះលំទោនទៅរកព្រះថេរៈចាស់ៗ រំពឹកដាស់តឿនពុំបាន ព្រោះយល់ខុសថា "មានតែខ្ញុំម្នាក់ទេ ដែលជូនព្រះមហាសត្វចេញទ្រង់ព្រះផ្នួស គ្រានោះ មិនឃើញលោកណាមួយជូនដំណើរព្រះអង្គទេ, ម្តេចឡើយក៏លោកទាំងនោះហ៊ានមកស្តីប្រដៅខ្ញុំ មិន

ព្រមស្តាប់ទេ ខ្ញុំស្តាប់តែព្រះអង្គ ១" ។ ព្រះសម្មាសម្ពុទ្ធក៏ទ្រង់ពុំស្តី ប្រដៅអ្វីឡើយ ដោយទ្រង់ជ្រាបថានិស្ស័យធម៌ពុំទាន់ដល់ ទើបទ្រង់ស្ងៀមៗ ចាំនិស្ស័យ ម្ល៉ោះហើយព្រះឆន្នៈ ក៏បេះតែក្អេងក្អាងដាក់ព្រះថេរៈចាស់ៗ ដែលជាវិន័យធរពហុស្សុត ស្តីព្រកដាស់តឿនអ្វីបន្តិចបន្តួចពុំបាន ។ លុះព្រះសម្មាសម្ពុទ្ធទៀបបរិនិព្វាន ទ្រង់មានព្រះពុទ្ធដីកាទឹងព្រះអានន្ទថា "អំណើះពីតថាគតទៅ ត្រូវអ្នកទាំងឡាយ ឲ្យព្រហ្មទណ្ឌដល់ឆន្នៈចុះ ទើបឆន្នៈលះអំពើមានះចេញបាន" ។ កាលព្រះអង្គបរិនិព្វានហើយភ្លាម ព្រះសង្ឃបានដាក់ព្រហ្មទណ្ឌដល់ព្រះឆន្នៈ គឺមត់គ្មា សូម្បីតែ ១ រូបក៏គ្មានលោកណានិយាយរកសោះឡើយ, ព្រះឆន្នៈទៅឯណាក៏គ្មានលោកណានិយាយរក លោកទាំងអស់សុទ្ធតែសំដែងមានះគប់ព្រះឆន្នៈគ្រប់រូប ។ កាលបើដូច្នោះ ព្រះឆន្នៈក៏នឹកសង្វេគថា "ឱ! អញដល់ម្ល៉េះតើ, គ្រាន់តែឥតពីព្រះដ៏មានបុណ្យទៅភ្លាម អញត្រមោចតែម្នាក់ឯង, ឱ! អំពើនេះព្រោះតែអញជាមនុស្សរឹងត្អឹងពេក បានជាដូច្នេះ" លុះដឹងខ្លួនហើយ ក៏លះមានះចេញ បន្ទន់ខ្លួនទន់លំទោនទៅរកសង្ឃតាមលំដាប់ចាស់ខ្ចីលន់តួដល់ព្រះថេរៈជាវិន័យធរ ពហុស្សុត សុំខមាទោសចំពោះអំពើដែលប្រព្រឹត្តល្មើសមកពីដើម ព្រះសង្ឃទាំងពួងក៏ជួយដាស់តឿនក្រើនរំឭកបន្តិចៗ ៦ រូប ព្រះឆន្នៈមានសេចក្តីសង្វេគ គេចចេញចាកពួកទៅចំរើនសមណធម៌ ក៏បានសម្រេចមគ្គផល ។

ដំណើរការ ប្តូរបៀបឲ្យព្រហ្មទណ្ឌដូចពោលមកហើយនេះ ក៏បាន ជាគតិមួយយ៉ាងប្រសើរដែរ ឈ្មោះថា "ឲ្យមានៈគបមានៈ" ត្រឡប់ជាផាត់មានៈបាន, ត្រូវគ្នានឹងសុភាសិតថា "ភ្លើងឆេះ ដុតភ្លើងគប" ដូចពោលមកខាងដើម ។

---

ព័ត៌មានថ្លែងសេចក្ដី

កាលទៅដឹកនាំយកព្រះពុទ្ធរូបនឹងបល្ល័ង្ក

នៅឃុំគន្ធបុរី ស្រុកព្រៃកប្បាស (តាកែវ)

## ឃុនបញ្ញាសោភ័ន គាំ-ឌុម

(រៀបរៀងតមកទឹងចប់)

## អំពីយកព្រះពុទ្ធរូបវត្តកំពង់ហ្លួង (អង្គរបុរី)

ក្ដីថាណាមនុស្សទាំងមកជួបជុំគ្នាច្រើន លុះរួចស្រេចកិច្ចបុណ្យកាលណា ខ្ញុំករុណាទាំងសុំនិមន្តព្រះពុទ្ធរូបពីក្នុងព្រះវិហារទៅដាក់លក្នុងទូក សូមព្រះតេជព្រះគុណអភ័យទោស សូមអនុញ្ញាតឲ្យមាន ១ ទៀតសូមឲ្យព្រះតេជព្រះគុណប្រាប់អ្នកស្រុកជើងវត្តឲ្យជួយឈើធ្លាលផង ព្រមទាំងទូកសួរបញ្ជាក់ថា ក្រៅអំពីព្រះពុទ្ធរូបក្នុងវិហារទៅ រកឃើញមានសុំអ្វីខ្លះទៀតផងឬ ? ១ ទៀតព្រះតេជព្រះគុណ សព្វព្រះទ័យឲ្យខ្ញុំករុណាយកអ្វីខ្លះទៀតមានផងឬ ?- ចំពោះចំណុចការបានសុំអត្ថាភាពតែព្រះពុទ្ធរូបបុរាណក្នុងវិហារ ១ អង្គប៉ុណ្ណោះ ក្រៅពីនោះមិនត្រូវសុំអ្វីទៀតទេ តែការនេះស្រេចនៅលើថេរៈ ទោះបីត្រូវការយកទាំងអស់តាមផ្ទះគេការអត្ថាភាពក៏មិនដឹងធ្វើដូចម្ដេច ប៉ុន្តែអត្ថាភាពសុំឲ្យចំពោះព្រះពុទ្ធរូបមួយៗ ដែលធ្វើអំពីឈើ ១ រូបគោ គោនន្ទិ ១ រូបមនុស្សអង្គុយក្បែររូបគោដែលអ្នកស្រុក

ហៅថាតាម៉ោង ១ កុំឲ្យសសរលីងពីវត្តពេក មួយទៀតដល់ថ្ងៃនិមន្តព្រះពុទ្ធរូប សូមឲ្យចីតាក់តែងចុះចំណែកអាគ្នាគាពពុំហានទៅជិតព្រះអង្គទេ ។

លុះដល់ថ្ងៃ ១៧ សេបតម្ប្រ៍ត្រូវនឹងថ្ងៃ ១៥ កេចខែកត្តិកជាថ្ងៃភ្ជុំបិណ្ឌ ជួបជុំអ្នកស្រុកជើងវត្ត ពួកខ្ញុំក៏បានតាក់តែងជញ្ជូនយករូបកំណាត់តូចធំទីងតារ៉ែកអក្សរ ១ ដុំនៃជដ្ឋីដាក់ក្នុងទូកជាមុនស្រេច ដល់ទេសនាជូនបង្ហើយបុណ្យភ្ជុំបិណ្ឌរួចហើយ វេលាម៉ោង ៣ រសៀលខ្ញុំក៏ដាក់ឲ្យមេឃុំរកមនុស្សគាស់ព្រះពុទ្ធរូបកិលចុះពីបល្ល័ង្កនិមន្តទៅដាក់ក្នុងទូករួចជាស្រេចក្នុងវេលាម៉ោង ៧ ល្ងាចដោយមានក្មេងស្មៀនទីងនៃឃុំហែហាមផង ។

ប្រមូលបុកណាគែ ដែលយកពីវត្តកំពង់ហ្លួងក្នុងពេលនោះទាំងប៉ុន្មានគឺព្រះពុទ្ធរូបធំក្នុងវិហារ ១ អង្គ, កំណាត់ខ្ទមនាងសាសនាព្រាហ្មណ៍ ៣, ព្រះកេសព្រះពុទ្ធរូបតូច ១, ព្រះកេសនាងសាសនាព្រាហ្មណ៍ ១, កំណាត់សសរទ្រូងធំម្ខារ ១, កំណាត់ដៃ-ជើងនិងកំណាត់ចង្កេះទៀត ៣៤, កំណាត់ដៃច្រើនក្រៀមពីសំរិទ្ធិតាស់បានមកពីក្រោមក្លោនខាងក្រោយព្រះពុទ្ធរូបធំក្នុងវិហារទម្ងន់ ២៣០ ក្រាម ១ និងកំណាត់ដៃនប៉ាក់ចំនួន ១៣ កំណាត់ផង, កំណាត់ចុងជើងយកពីទួលក្អែក ១, ព្រះកេសព្រះពុទ្ធរូបយកពីទួលវត្តកកាងវ ១, មានកំណាត់ខ្ទមតូចៗ ២ កំណាត់និងកំណាត់ចុងជើង ១ ដែលបានមកពីក្នុងវត្តដូនវង្សា ដោយលោកគ្រូគុងអៀកម៉ាបានឲ្យមកពីថ្ងៃមុនផង ។

កាយកព្រះពុទ្ធរូបវត្តកំពង់ហ្លួងនេះបានដោយពិបាកបន្តិច ព្រោះមនុស្សទាំងប៉ុន្មានគ្មានអ្នកណាមួយហ៊ានគាស់រំលើងបល្ល័ង្កយកព្រះពុទ្ធរូបនោះឡើយ សង្កេតមើលទៅមកពីខ្លាចបាញ់បារមីព្រះពុទ្ធរូបនោះក្រែងធ្វើខ្លួនឲ្យស្លាប់ឬឲ្យឈឺថ្កាត់ពុំនោះឲ្យវិនាសអន្តរាយផ្សេងៗ លុះតែគេជួលជាងជាតិយួនម្នាក់ឲ្យគាស់ទើបសម្រេចបាន អ្នកកាន់ព្រះពុទ្ធសាសនាក្នុងស្រុកខ្មែរ ច្រើនតែគោរពកោតខ្លាចព្រះពុទ្ធរូបតាមទំនងដែលនិយាយខាងលើនេះឯង មានតែខ្លះខ្លាចព្រះពុទ្ធរូបរហូតដល់ទៅមិនហ៊ានបោសសំអាតបល្ល័ង្កឬទីវិហារឲ្យស្អាតល្អឡើយ ទុកឲ្យនៅស្មុគស្មាញដោយជើងធូបគរពេកកាយទាំងសំរាមធូលីគ្របព្រះពុទ្ធរូបទាំងទីវិហាររកតែពន្លឺល្មមឲ្យអង្គុយថ្វាយបង្គំព្រះពុទ្ធរូបគ្មាន ប្រសិនបើព្រះពុទ្ធព្រះអង្គជាមនុស្សកាចធ្វើសត្វឲ្យស្លាប់ឲ្យឈឺឬឲ្យអន្តរាយផ្សេងៗ មែន តើអ្នកណាគេនឹងគោរពប្រណិប័តន៍ ហើយសន្ធាតកសាងព្រះពុទ្ធរូបបិទមាសយ៉ាងល្អទាំងចំណាយប្រាក់កប់ម៉ឺនធ្វើវិហារដំបល់ទៀតជាប្រយោជន៍អ្វី ? យើងគោរពប្រណិប័តន៍ព្រះពុទ្ធរូបប្រយោជន៍យកបុណ្យ ដែលហៅថាបុណ្យគឺសេចក្តីល្អបរិសុទ្ធដែលយើងបានធ្វើដោយកាយវាចាចិត្តចំពោះព្រះពុទ្ធ; ឯពាក្យថាកាច, ធ្វើឲ្យស្លាប់ឬឲ្យអន្តរាយជាអំពើបាបអាក្រក់ ចុះបើយើងថ្វាយបង្គំព្រះពុទ្ធរូបឬពុំហ៊ានបោសសំអាត ដោយយកពាក្យអាក្រក់មកគិតថាព្រះអង្គកាច ធ្វើឲ្យស្លាប់ឲ្យអន្តរាយហើយ តើនឹងឲ្យឈ្មោះថាបាន

បុណ្យមកពីណា ? ឯការខ្វះគកាយព្រះពុទ្ធរូបនោះ លុះតែធ្វើដោយចេតនាប្រកបដោយបំផ្លិចបំផ្លាញបោលៈ ទើបគួរឲ្យខ្លាចមែន ចុះបើខ្វះកកាយដោយកុសលចេតនា ប្រកបនឹងជួសជុលឲ្យល្អឡើងវិញកិលផ្លាស់ទីកន្លែងប៉ុណ្ណោះ តើអ្នកប្រាជ្ញខាងពុទ្ធសាសនាណា ហាមឃាត់សេចក្ដីថាបាបបាន? ។

រឿងនេះ ខ្ញុំបានទូលលោកគ្រូជាអធិការនៃអ្នកស្រុកជើងវត្តខ្លះតាមផ្លូវធម៌ដើម្បីបន្ទន់ចិត្តអ្នកស្រុកថា ការដែលយើងស្រឡាញ់ព្រះពុទ្ធរូប ហើយទុកសម្រាប់គោរពថ្វាយបង្គំតែម្នាក់ឯង ឬចំពោះតែស្រុកមួយៗ ឈ្មោះថាយើងកំណាញ់បុណ្យ ព្រោះកាលការស្រឡាញ់ព្រះពុទ្ធរូបដែលជាបុរាណវត្ថុណាស់ គំពុងតែគេប្រមូលយកទៅទុកនៅសារមន្ទីរកំពេញ ដើម្បីរក្សាទុកឲ្យបានគង់នៅល្អផង សម្រាប់ឲ្យសាធារណជនថ្វាយបង្គំយកបុណ្យផង ពេលបើយើងជូនទៅកជតារហើយវុកដូចជាបានធ្វើបុណ្យទីធកជតារឬចំពោះទីអ្នកនគរទាំងមូល ព្រោះកជតារយកទៅទីដំកល់ទុកក្នុងសារមន្ទីរក្នុងពេញ ដែលមានមនុស្សចេញចូលមួយថ្ងៃៗ រាប់រយនាក់ កាលបើបានឃើញព្រះពុទ្ធរូបរបស់យើង ហើយគេនឹងលើកដៃថ្វាយបង្គំគ្រប់គ្នា ចំណែកបុណ្យវិញក៏នឹងកើតមាន ដល់យើងជាម្ចាស់រាល់ៗមនុស្សដែលថ្វាយបង្គំ តបើ ១ ថ្ងៃមានគេថ្វាយបង្គំ ១០០ ដង បុណ្យនឹងបានដល់យើង ១០០ ដងក្នុងថ្ងៃនោះដែរ ។

ចំណែកព្រះពុទ្ធរូបបើយើងជូនដល់ការគោរពដោយចិត្តជ្រះថ្លា យើងនឹងបានបុណ្យពីការនោះផង បានបុណ្យអំពីមនុស្សណាដែលទៅថ្វាយបង្គំព្រះពុទ្ធរូបរបស់យើងផង១ទៀត ជាហេតុនាំឲ្យយើងមានឱកាសធ្វើបុណ្យចំណាយប្រាក់ កសាងព្រះពុទ្ធរូបដទៃទៀតដំកល់ឡើងសម្រាប់ថ្វាយបង្គំយកបុណ្យតទៅទៀតផង ឯការសោកស្តាយនោះគឺដោយសេចក្តីយល់ខុសជាប្រាកដ បើតាមពិតវិញនោះត្រូវយល់ថា ស្រុកអង្គរបុរីនេះដែលពួកជគារត្រូវការចេញចូលញឹកញយទាំងបានរៀបរយ បន្តិចឡើងនេះ អាស្រ័យដោយគុណដុំឥដ្ឋដុំថ្មនឹងរូបដែលជារបស់ពីបុរាណប៉ុណ្ណោះ អស់លោកអស់អ្នកទាំងឡាយត្រូវយល់តទៅទៀតថា អំណើះតទៅមុខទៀត ប្រសិនបើពួកការមករៀបចំតាក់តែង ស្រុកនេះឲ្យថ្កុំថ្កើងរុងរឿងមានរបៀបរៀបរយសម្បូណ៌សប្បាយឡើងនោះ ក៏អាស្រ័យដោយសារគុណដុំឥដ្ឋដុំថ្មអំបែងភាជនៈ ឬខ្លួនរូបថ្មបុរាណដែលជាមត៌កនៃបុព្វ-បុរសរបស់យើងបានសាងទុកជាសម្បត្តិឲ្យសុខដល់យើង ដោយពួកការបានមកប្រមូលយករូបនឹងចារឹកអក្សរជាដើមទៅទុកនៅសារមន្ទីរភ្នំពេញ ហើយពិនិត្យរកពង្សាវតារទៅឃើញថា គួរនឹងរៀបចំធ្វើឲ្យទៅជាទីរម្មណីយដ្ឋានល្អឡើង ៗ កាលដែលខ្ញុំនិយាយយ៉ាងនេះទៅវិញនោះ អ្នកស្រុកខ្លះដែលបានឮហើយចូលចិត្តស្តាប់បានច្រើនដែរ ប៉ុន្តែមិនដាច់ចិត្តនៅតែអាល័យមមៃមមាញឹកនឹកពុំភ្លេច ៗ

## អំពីអ្នកបល្ល័ង្កធំដែលមានសិលាចារឹកនៅទួលសែនស្នុត

ដល់ថ្ងៃ ១៨ សេបតមប្រ៍ គេឲ្យប់ទៅយកបល្ល័ង្កធំ ១ ទំហំ ១ ផ្ទៃ ១ ម. ១០ កំពស់ ០ ម. ៩៥ មានសិលាចារឹកនៅផ្ទៃទាំង ៣ ដែកល់នៅជាប់នឹងទួលសែនស្នុតត្រង់ទិសអគ្នេយ៍បុរីខាងត្បូងមាត់ស្ទឹងបន្ទាយប្រហែល ១០០ ម. ដែលបានរំកិលយកពីថ្ងៃ ១៥ នឹង ១៦ សេបតមប្រ៍ ២ ថ្ងៃរួចម្ដងហើយ ប៉ុន្តែដោយហេតុថ្មនោះធំធ្ងន់ណាស់ ទាំងមនុស្សអ្នកធ្វើការក៏ទៀបហត់ កាលពីធ្វើបុណ្យនោះផង មិនបានជួបជុំគ្នាច្រើន បានជារំកិលមកបានដោយយឺតយូរបន្តិច ២ ថ្ងៃបានឃ្លាតពីកន្លែងដើមជាងពាក់កណ្ដាលទីប៉ុណ្ណោះ ហើយក៏បង្អង់ទុកសិន បានគេឲ្យប់ទៅយកព្រះពុទ្ធរូបវត្តកំពង់ហ្លួងវិញ ព្រោះថ្ងៃ ១៧ សេបតមប្រ៍ជាថ្ងៃភ្ជុំបិណ្ឌ អ្នកស្រុកមកជួបជុំច្រើន ឯបល្ល័ង្កធំនោះបម្រុងជានឹងយកទៅដាក់ក្នុងទូកឲ្យហើយស្រេចក្នុងថ្ងៃ ១៨ សេបតមប្រ៍តែម្ដង លុះដល់កាត់ស្ពានស្រាប់តែបិនម្ចាស់ទូក ឃើញថ្មនោះធំពេកក៏ប្រកែកពុំព្រមឲ្យដាក់ក្រែងធ្ងន់ធ្លាយទូក ឲ្យបិននោះរកជួលទូកដទៃទៀតក៏រកពុំបាន ឲ្យមេឃុំអង្គរបុរីរកជួលទៀតក៏ពុំបានដែរ ប៉ុន្តែខ្លាចថ្មនោះពុំហ៊ានជួលទូកឲ្យដាក់សោះ ម្ល៉ោះហើយនាំឲ្យខ្ញុំអស់សង្ឃឹមថានឹងរកបានទៀត បានជាខ្ញុំនឹងលោកគី - គឹមស៊ីវ ចេញទៅតាកែវក្នុងថ្ងៃ ១៩ សេបតមប្រ៍ដើម្បីជំរាបដល់ព្រះបាទម្ចាស់ចៅហ្វាយខេត្រតាកែ

ខឹងនិយាយទូរសព្ទជំពប់ដល់លោកអគ្គលេខាធិការនៃពុទ្ធសាសនបណ្ឌិត្យឯភ្នំពេញឲ្យបានជ្រាបផង បើយ៉ាងហ្នឹងគេនឹងធ្វើដូចម្តេច ចំណែកព្រះបាទម្ចាស់ចៅហ្វាយខែត្រតាកែវ ឃើញខ្ញុំចូលទៅដល់សួរដឹងសេចក្តីហើយលោកមានអធ្យាស្រ័យមិនសប្បាយសោះ ទើបលោកអញ្ជើញចូលទៅជួបនឹងលោកឡឺរេស៊ីដង់ត៍ ជំរាបតាមដំណើរហើយក៏សរសេរសំបុត្រ ១ ច្បាប់បង្គាប់ទៅមេឃុំនឹងសេហ្ស៊ូប៉ុស្ដ៍ឲ្យខំខ្វល់ខ្វាយរកទូកដាក់ថ្មនោះឲ្យបានទើបសមគួរតាមផ្លូវរាជការ ហើយឲ្យខ្ញុំនឹងលោកគី-គឹមស៊ុរត្រឡប់ទៅអង្គរបុរីវិញ ។

ថ្ងៃ ២០ សេបតមប្រ៍វេលាម៉ោង ៨ ព្រឹកខ្ញុំនឹងលោកគី-គឹមស៊ុរក៏ចេញពីតាកែវត្រឡប់ទៅអង្គរបុរីវិញ ម៉ោង ៣ រសៀលទើបបានដល់អង្គរបុរីហើយយកសំបុត្រទៅជូនមេឃុំនឹងលោកសេហ្ស៊ូប៉ុស្ដ៍បានមើលសព្វគ្រប់ហើយទើបមេឃុំទៅជួលទូកចិនម្នាក់ នៅអង្គរបុរីដែលកាលពីដើមមិនហ៊ានយកមកដាក់ថ្មនោះដោយយល់ថាតូចពេក លុះជួលបានហើយក៏ប្រគល់ឲ្យជាងយួនម្នាក់ជាមេទូលរៀបចំដាក់ថ្មក្នុងទូកនឹងនាំរហូតដល់ភ្នំពេញផង ក្នុងវេលាម៉ោង ៧ កន្លះល្ងាចថ្ងៃ ២០ សេបតមប្រ៍នោះក៏បានចាត់ចែងដាក់ថ្មក្នុងទូកហើយជាស្រេច ការយកព្រះពុទ្ធរូបនឹងបល្ល័ង្កអស់ត្រឹមប៉ុណ្ណេះ ។

## អំពីដំណើរចេញពីអង្គរបុរី

ថ្ងៃ ២១ សេបតឹមប្រ៍ វេលាម៉ោង ១១ ព្រឹកទទួលទានអាហាររួច ហើយលោកមេឃុំបានឲ្យសេនក្មេងសៀមថ្វាយព្រះពុទ្ធរូប ជូនដំណើររួច ទើបឲ្យទូកចាំង ៣ បញ្ចេញពីអង្គរបុរីចុះទៅចូដុក (មាត់ជ្រូក) ដើម្បីទៅចាំសំពៅនកប៉ាល់ពីទីនោះមកភ្នំពេញ ព្រោះទឹកហូរខ្លាំងវែរប្រាស ទឹកពុំរួច ឯលោក អ៊ុក-សេន និង សៅ-សឿង បានឲ្យមកជាមួយនឹងទូកដើម្បីរក្សាបុរាណវត្ថុដែលនាំមកទាំងអស់ ចំណែកខ្លួនខ្ញុំនិងលោក គី-គឹមស៊ីរ ក៏ចេញពីអង្គរបុរី ត្រឡប់មកតាកែវវិញ ក្នុងពេលជាមួយគ្នានោះឯង ដោយមានការត្រូវបង្ហួសទៅពិនិត្យមើលសិលាចារឹកនៅប្រាសាទភ្នំបាយង់ (ស្រុកគិរីវង្សតទៅទៀត) លុះបានទៅដល់តាកែវចូលទៅជំរាប ប្រប៉ាងម្ចាស់ចៅហ្វាយខេត្តតាមដំណើរសព្វគ្រប់ហើយលោកមានចិត្តសោមនស្សរីករាយសប្បាយច្រើនណាស់ ដោយលោកបានខ្វល់ខ្វាយចាត់ការនាំបុរាណវត្ថុ បានសម្រេចដោយចេស្តានុភាពរបស់លោក រួចទើបលោករៀបចំដំណើរឲ្យទៅភ្នំបាយង់ក្នុងថ្ងៃស្អែកទៀត ។

## អំពីដំណើរទៅភ្នំបាយង់ស្រុកគិរីវង្ស ( តាកែវ )

ថ្ងៃ ២២ សេបតឹមប្រ៍ វេលាម៉ោង ៧ ព្រឹកខ្ញុំនិងលោកគី-គឹមស៊ីរ បានចេញដំណើរពីតាកែវសំដៅទៅស្រុកគិរីវង្សដោយរ៉ឺម៉ក រសៀលម៉ោង ១ បានទៅដល់ផ្សារទន្លាប់ចម្ងាយផ្លូវពីតាកែវទៅ ៤០ គីឡូម៉ែត្រ

ឈប់សម្រាកទទួលទានបាយហើយខ្ញុំក៏ជូនលោក គ-គឹមស៊ីវ ឲ្យនៅចាំទីផ្សារទន្លាប់ ម៉ោង ៣ រសៀលខ្ញុំក៏ចេញពីនោះបង្ហួសទៅសាលាស្រុកគិរីវង្ស ចម្ងាយផ្លូវ ១៤-គីឡូម៉ែត្រទៀត ដើម្បីទៅជួបនឹងលោកចៅហ្វាយស្រុកតាមបណ្តាំចៅហ្វាយខេត្ត លុះរសៀលម៉ោង ៤ កន្លះបានទៅដល់សាលាស្រុកគិរីវង្សយកសំបុត្រ ១ ច្បាប់ ដែលចៅហ្វាយខេត្តផ្ញើទៅៗ ជូនលោកចៅហ្វាយស្រុកៗ មើលរួចហើយ ក៏ជូនខ្ញុំត្រឡប់មកផ្សារទន្លាប់វិញភ្លាម ដោយលោកមានដំណើរទីណែយត្រូវទៅដាក់ឃ្លាំងនៅតាកែវក្នុងវេលានោះផង លោកបាននាំខ្ញុំទៅជួបនឹងលោកមេឃុំៗព្រះបាទជាំងជុំ នឹងលោកគ្រូសុក-ហាង មេគណវត្តក្រោម (វត្តឧទុម្ពរ) តែពេលនោះលោកគ្រូមេគណមិននៅនិមន្តទៅស្រុករមេញ ទើបលោកចៅហ្វាយស្រុកផ្ញើសំបុត្រ ១ ច្បាប់ផ្ញើទៅលោកគ្រូមេគណឲ្យបានជ្រាបដោយខ្លួន ១ ដែលមកពីស្រុកនោះ បានប្រគល់កិច្ចការរបស់ខ្ញុំចំពោះលោកមេឃុំឲ្យជួយខ្វល់ខ្វាយរួចហើយ ព្រឹកឡើងទើបលោកអញ្ជើញមកតាកែវ ។

## អំពីដំណើរមើលវត្តលើ (វត្តពោធិវង្ស)

ថ្ងៃ២៣ សេបតមប្រ៍ពេលព្រឹកម៉ោង៩ បានទៅមើលសិលាចារឹក ២ ផ្ទាំងនៅវត្តលើ មានលោកមេឃុំនឹងប៉ូលិសម្នាក់ឈ្មោះទៀងដែលបានភ្ជាប់ស្គាល់មកយូរហើយជូនទៅជាមួយផង លុះទៅដល់វត្តនោះ លោក

គ្រូចៅអធិការមិនទៅទីបន្ទរពៅគាន់ដុះ១បាសក ឃើញនៅតែលោកគ្រូសូត្រឈ្មោះមាស បានធ្វើបដិសណ្ឋារៈទទួលរាក់ទាក់ឲ្យក្មេងបេះដូងឲ្យទទួលទានទឹកដូងហើយ ទើបលោកនាំមើលអស់ទាំងថ្មជាបុរាណតែប៉ុន្មានដែលមានក្នុងវត្តនោះ ខ្ញុំបានពិនិត្យមើលសព្វឃើញក្រៅអំពីចារឹកអក្សរ ២ ផ្ទាំងទៅនៅមានផែនថ្មផ្ទះគ្រឿងប្រដាប់ប្រាសាទ មានថ្មមេទ្វារជាដើមចំនួន ១៧, មានទ្រនាប់ជើងជណ្ដើរ ១ បល្ល័ង្ក ១ ស្នានទ្រោណី ឬទមាយោនី ១ រូបសិង្ហ ៣ ក្បាច់ក្បាលនាគសម្រាប់បន្ទបលើជ្រុងថែងប្រាសាទមាន ២, នឹងមានផែនថ្ម ៣ ទៀតកាត់មូលទ្រវែងបណ្ដោយ ១ ម.២៨ ទទឹង ០ ម. ៧២ កំពស់ ០ ម. ០៨ ផ្ទៃខាងលើជុំវិញអមខាងមានលកខូងជ្រៅខ្លះរាក់ខ្លះមានសណ្ឋានផ្សេងៗគ្នា អ្នកស្រុកហៅថាថ្មព្រះបាទជាន់ជុំ ខ្លះថា ជើងប្រជុំ ដោយស្គាល់ថាជាស្នាមជើងដែលជាន់ជុំវិញ ទាំងឈ្មោះឃុំទៀតក៏ឲ្យឈ្មោះតាមថ្មនោះដែរ ( ឃុំព្រះបាទជាន់ជុំ ) ប៉ុន្តែខ្ញុំបានសង្កេតមើលថ្មនោះសព្វហើយ មិនឃើញមានទំនងល្មមឲ្យស្គាល់បានថាជាស្នាមជើងអ្វីសោះ ដែលហៅថ្មនោះប្រហែលជាដោយសន្មតរបស់អ្នកស្រុកទេដឹង? ថ្មនោះសព្វថ្ងៃបែកជា ៦ កំណាត់គ្រាន់តែផ្គុំទល់គ្នាទុកនៅលើសាលាវត្តនោះ ខ្ញុំឃើញហើយនឹកស្ដាយណាស់ក្រែងតែទៅនឹងវិនាសបង់ដោយគ្មានគេថែរក្សា ព្រោះកន្លែងដែលទុកដាក់សព្វថ្ងៃក៏មិនបានសមគួរដែរ បំណែកថ្មបាយក្រៀមដែលជាគ្រឿងប្រដាប់ប្រាសាទ

បុណ្យក៏នៅសល់ច្រើន តែមានខ្លះទើបនឹងធ្វើខាងក្រោយ ក្នុងវិហារមានព្រះពុទ្ធរូបធ្វើអំពីថ្ម ៤ អង្គដែលជាស្នាដៃពីបុរាណ ត្រង់ទីវិហារជាពន្លូនរបស់ប្រាសាទបុរាណ ១ លុះដើរមើលសព្វហើយទើបបានទៅថ្វាយបង្គំលោកគ្រូចៅអធិការដែលទើបនឹងនិមន្តមកពីផ្ទះឧបាសក វេលាដែលលោកត្រឡប់វិលវិញ លោកប្រស្រក្រដាសបានឲ្យរូបស្វាហនុមាន ១ ធ្វើអំពីសំរិទ្ធជារូបឈរចេញឆាក់សំដែងឫទ្ធិ មានកំពស់ ០ ម. ១៦ ទម្ងន់ ១០៣២ ក្រាមបានមកអំពីទួលអ្នកតាតាកើងធំ ដោយឧបាសកម្នាក់ឈ្មោះប៉ាយ-ជ្រែក បានកាប់ដីក្បែរទួលនោះ, នៅចុងឫស្សីដល់បុរាណដៃទៃលើកជាប់ពីប្រាសាទភ្នំបាយ៉ង់ ធ្វើស្រែសណ្តែកបានឃើញរូបនោះហើយក៏យកទៅប្រគេនលោកឲ្យរក្សាទុក ។

## អំពីដំណើរទៅជួបនឹងលោកគ្រូមេគណវត្តក្រោម

ក្នុងវេលាល្ងាចថ្ងៃ ២៣ នោះ លោកគ្រូមេគណបាននិមន្តពីស្រុករមេញ (ឈ្មោះអណ្តែត) វិញ ខ្ញុំក៏បានទៅថ្វាយបង្គំទូលលោកតាមដំណើរថា ខ្ញុំករុណាដែលមកនេះដោយមានសំបុត្រ ១ ច្បាប់ពីលោកឡឺរ៉េស៊ីដង់តាកែវទៅជំរាបលោកអគ្គលេខាធិការនៃពុទ្ធសាសនបណ្ឌិត្យថា ព្រះតេជព្រះគុណបានជំរាបលោកឡឺរ៉េស៊ីដង់ថា បានឃើញសិលាចារឹក ២ ផ្ទាំងនៅកណ្តាលប្រាសាទភ្នំបាយង់ កប់នៅក្នុងដីគ្មាននរណាដែលឃើញទេ ឥឡូវនេះលោកអគ្គលេខាធិការពុទ្ធសាសនបណ្ឌិត្យចាត់

ឲ្យខ្ញុំករុណាមកពិនិត្យអក្សរចារឹកនោះហើយឲ្យថតយកទៅផង ប្រសិនជាមានមែន មានសេចក្ដីរៀបរាប់ល្អពេក ខ្ញុំនឹងប្រគេនរង្វាន់ដល់ព្រះតេជ-គុណ ឯលោកគ្រូមេគណក៏មានព្រះពុទ្ធដីកាតបមកខ្ញុំវិញថា កាលដែលអាត្មាភាពជាប់លោកឡើងទៅសុំផងគឺតាំងនោះពុំមែនជាបានឃើញសិលា-ចារឹកទេ អាត្មាភាពគ្រាន់តែដឹងតែលឺគេដំណាលថា នៅកណ្ដាលប្រាសាទភ្នំបាយ៉ង់មានផែនថ្ម ២ ផ្ទាំង គ្មាននរណាដែលគាស់មើលទេ ប្រហែលជាមានរបស់អ្វីនៅខាងក្រោមផែនថ្មនេះ?

## អំពីទៅមើលប្រាសាទលើភ្នំបាយ៉ង់

លុះដឹងថាមិនពិតដូច្នោះហើយ ខ្ញុំក៏នៅតែមិនទាន់អស់ចិត្តចង់ទៅមើលឲ្យឃើញច្បាស់ដោយខ្លួនឯង លោកគ្រូមេគណឃាត់ខ្ញុំកុំឲ្យទៅ បានជួបតែត្រឹមលោកប៉ុណ្ណោះបានសេចក្ដីហើយ ព្រោះផ្លូវឡើងទៅមើលប្រាសាទលើភ្នំបាយ៉ង់នោះ រដូវនេះពិបាកឡើងទៅណាស់ ព្រោះឈើឬស្សីព្រៃបន្លាទ្រនុំខ្នានខែត្រដុះកាត់ផ្លូវបង្អៀតណាស់ ប្រៀបមិនចុះ ១ ទៀតក្រែងប្រទះទៅការលើសំបុកសត្វកកែ ព្រោះសត្វនោះវាកាចណាស់ហើយសូម្បីតែ ១ ក៏អាចធ្វើឲ្យគេងាប់បាន ឯសត្វពស់អាសិរពិសក៏គគ្រឹកផ្លូវនេះច្រើនសម្បូរណ៍ណាស់ដែរ តាមផ្លូវកណ្ដាលកាច់ (ផ្លូវបុរាណ) នោះតោះគណាសរបេះបើកអស់ហើយគ្មាននរណាដែលហានឡើងទេ ចំណែកខ្លួនខ្ញុំក៏-គិតសុំឲ្យនៅនឹងសាលាឃុំដោយមិនផ្ញើខ្លួន ក៏សុំខ្លួនទៅមើលឲ្យឃើញច្បាស់

ដោយព្រួយបារម្ភណាស់ តែកន្ទាយទៅហ្វាយ៉េបន្ទោសថាទៅដល់ហើយ ម្តេចក៏មិនទៅមើលឲ្យជាក់ច្បាស់ដោយខ្លួនឯងផង ដោយខ្លួនខ្ញុំបង់ទៅមើលបុកណាវត្តដែលមិនទាន់បានឃើញផង ។

ថ្ងៃ ២៤ សេបតមប្រ៍វេលាម៉ោង ៧ ព្រឹកខ្ញុំក៏ចេញពីសាលាឃុំនៅផ្សារទន្ទាប់ទៅជាមួយនឹងអ្នកស្រុក ៣ នាក់ ដែលមេឃុំចាត់ឲ្យជូនទៅ ចម្ងាយពីផ្សារទន្ទាប់ទៅដល់ជើងភ្នំ ៣០០០ ម. ឡើងពីជើងភ្នំទៅដល់ប្រាសាទតាមផ្លូវដែលកដការធ្វើបត់ចុះឡើងចម្ងាយប្រហែល ៣០០០ម. ទៀត ប៉ុន្តែដើរកាត់ផ្ទាំងតាមផ្លូវញាតស្បាតខ្លះ ក៏ដំណើរដែលឡើងភ្នំបង់តាប់ទុកជាមេឃស្រទំហើយមានឈើមសស្រែបផង ក៏នៅតែបែកញើសហូរស្រោក់ជោគខោអាវទៅជាងនឹងតម្ងបង់ខ្យល់តាប់ ទឹកស្ពានជាប្រហែលជាទៅមិនដល់តែដោយបុណ្យកុសលប្រឹងដើរបន្តិចទៅបានដល់ទីកបស្ពាន ១ ជាកន្លែងដែលកដការធ្វើសាលាមួយសម្រាប់សំណាក់យកខ្យល់អាកាស លើភ្នំនោះខាងកាយប្រាសាទភ្នំបាយង់ចម្ងាយប្រហែល ៦០០ម. ឯសាលានោះភ្លើងឆេះអស់ ហើយនៅសល់តែសសរ ខ្ញុំក៏ឈប់សម្រាកនៅទីនោះបន្តិចបានត្រៃខ្យល់អាកាសត្រជាក់មានកំឡាំងស្រួលខ្លួនហើយក៏ខំប្រឹងឡើងទៅទៀត ដើរបន្តិចទៅបានឃើញប្រា-សាទ ១ ធ្វើអំពីឥដ្ឋទំហំ ៤ ម. ៥០ បួនជ្រុងទៀនខាងក្រោមតម្កល់នៅកន្លែងឈមមុខខ្លោះទៅកេប្រាសាទភ្នំបាយង់ ដែលនៅលើកំពូលភ្នំខាងទិស

ពាយ័ព្យ ប្រាសាទនោះគប់នៅក្នុងព្រៃស្ងាត់ជិតឈើង អ្នកស្រុកហៅថា ប្រាសាទព្រះគោ ខ្ញុំបានចូលទៅមើលតែមិនមានវត្ថុវិសេសអ្វីល្អមគត់ទុកជាសំគាល់បានទេ ១ ទៀតព្រៃដុះស្និទ្ធជិតណាស់មិនអាចនឹងប្រៀតជ្រែកគេមើលឲ្យឃើញច្បាស់បានឡើយ រួចហើយក៏ឡើងបន្ហួសទៅទៀតដល់ប្រាសាទលើកំពូលភ្នំបាយង់ វេលាម៉ោង ១០ ព្រឹក ឯទីជុំវិញប្រាសាទដែលបានកាប់ឆ្កាគាស់គាយចេញមុនហើយនោះ ឥឡូវនេះឈើនឹងទន្ទ្រានខែត្រដុះស្និទ្ធជិតឡើងវិញ តែនៅល្មមវែកញែកគេមើលដោយកន្ទេងបានខ្លះ ចំណែកប្រាសាទនោះធ្វើអំពីថ្មទំហំបណ្ដោយ ១០ ម. ទទឹង ៧ ម. ៨០ បែរមុខទៅខាងទិសអាគ្នេយ៍ ត្រង់កណ្ដាលផ្ទៃប្រាសាទមានរៀបជាបន្ទប់ ១ តូចមានទំនងដូចជាប្រាសាទតូច ១ ដែលធ្វើជាយូរហើយដល់តមកខាងក្រោយធ្វើប្រាសាទ ១ ធំគ្របពីលើទៀត តែគេមិនបានរុះរើប្រាសាទមុនចោលទុកឲ្យនៅធ្វើជាបន្ទប់ខាងក្នុង ខាងមុខមានរៀបជាមង្ហាឬយ៍តភ្ជាប់មកពីតួប្រាសាទសងខាង មានវែវបត់បែនផង ឯការធ្វើខាងក្រៅទាំងប៉ុន្មានសុទ្ធតែធ្វើអំពីថ្មបាយក្រៀមទាំងអស់ ហើយរលំរលើងទាំងអស់នៅសល់តែសសរទ្រនិងជញ្ជាំងខ្លះប៉ុណ្ណោះ ត្រង់កណ្ដាលបន្ទប់ក្នុងផ្ទៃប្រាសាទនោះមិនឃើញមានផែនថ្ម ២ ផ្ទាំងដូចលោកគ្រូមេគណនិយាយទេ មានតែថ្មបាយក្រៀមធំៗទំហំប្រហែល ០ ម. ៥០ បួនជ្រុងច្រើនដុំក្រាលត្រង់កណ្ដាល ហើយមានកំណាត់ក្បាច់និងកំណាត់រូបជា

ច្រើននៅត្រង់កន្លែងនោះមានផែនថ្មខៀវ ៤ ផ្ទាំងដាក់តគ្នាពីមាត់ទ្វារខាងក្រៅចូលទៅបន្ទប់ខាងក្នុង ខាងមុខប្រាសាទមានបល្ល័ង្ក ២, កំណាត់ចុងជើងឈរជាប់នឹងទ្រនាប់ ១ រូបស្រី ១ នៅតែពីត្រឹមពោះទៅជើងបញ្ឈរជាប់នៅលើបល្ល័ង្ក ក្បាលនឹងដៃទាំងពីរបាក់បាត់ នៅថែវខាងលិចឃើញមានក្បាច់ខ្លោងទ្វារ (linteau) ១ ។

នៅទីប្រាសាទនោះ បើបានឡើងទៅដល់ហើយគួរឲ្យសប្បាយរីករាយណាស់ព្រោះក្រឡេកមើលទៅទិសបូព៌ស្ថានទីខាងកើត ឃើញតែវាលទីងបឹងសន្ធឹងល្ហល្ហេវមើលដាច់កន្ទុយភ្នែក បើមើលទៅទិសដទៃទៀតឃើញតែខ្នងភ្នំជាប់គ្នាជិតទាបខ្លះខ្ពស់ខ្លះ ឃើញតែចុងឈើ និងស្មៅប្រួងប្រាងមិនឃើញដល់ដីគោកទេ ហើយបណ្ដាលចិត្តឲ្យស្រងេះស្រងោចខ្លោចផ្សាទឹកលើកដល់បុព្វបុរសណាដែលកសាងប្រាសាទនោះ ដូចវត្ថុធម្មជាតិដែលធ្វើរណតាពទៅ ទុកតែស្នាដៃវិសេសឲ្យកូនមើលដល់មតិចនោះខូចខាតទៅ កូនមិនអាចនឹងធ្វើដូចម្ដេចឲ្យបានដូចដើមវិញ ។ ១ ទៀត នៅលើកំពូលប្រាសាទបាយ័នមានខ្យល់អាកាសស្រួលណាស់ មានពពកសជាត់មកដោយខ្យល់ទាំងជុំ ៗ ធ្វើឲ្យត្រជាក់ត្រជុំត្រជាប់សព្វសាច់រហូតដល់ឆ្អឹងប្រមាត់បេះដូង នាំឲ្យស្រួលខ្លួនមានកំឡាំងបាត់ឃ្លានអាហារ ។

លុះខ្ញុំដើរមើលទីនេះទៅសម្រាកប្រហែលជាង ១ ម៉ោងដល់ម៉ោង ១១ កន្លះព្រឹកខ្ញុំក៏ត្រឡប់ចុះមកវិញ ទៅព្រៃក្នុងនោះសម្បូណ៌ដោយផ្លែព្រលទុំក្រហមពាសពេញព្រៃ អ្នកស្រុកទាំង ៣ នាក់ដែលជូនខ្ញុំទៅប្រញាយគ្នាបេះទទួលទានហើយបងបាច់ចាំងបង្កោម ១ ផ្ញើកូនប្រពន្ធ ខ្ញុំក៏បានទទួលទានខ្លះដែរ ផ្លែព្រលមានរសជាតិជូរឯម ហើយត្រជាក់ស្រួលណាស់ បរិ-ភោគទៅកាលណាមិនឲ្យទោសទេ. ដោយចុះពីលើភ្នំដើរស្រួលហើយច្រើនតែដើរកាត់តំរង់ផង ម៉ោង ២ រសៀលក៏បានដល់ទៅសាលាឃុំនៅផ្សារទន្ទាប់ . ទទួលទានបាយរួចចូលទៅលាលោកគ្រូមេគណវត្តក្រោម វេលានោះលោកបានឲ្យត្រាប់កាំភ្លើងធំ ៣ មានទម្ងន់ ១.១១២ ក្រាម ជីកបានមកពីកងដីទៅទីវត្តនោះ ឲ្យយកមកជូនលោកអគ្គលេខាធិការនៃពុទ្ធ-សាសនបណ្ឌិត្យទុកជាសម្បត្តិនៃសារមន្ទីរខ្មែរភ្នំពេញ ។ រួចហើយខ្ញុំសរ-សេរសំបុត្រ ១ ច្បាប់ទុកឲ្យមេឃុំផ្ញើទៅជូនលោកចៅហ្វាយស្រុក ជំរាបអំពីការ ដែលខ្ញុំបានទៅមើលនិងអំណោយដែលបានទទួលអំពីលោកគ្រូមេគណវត្តក្រោមនិងលោកគ្រូសូត្រវត្តលើ រួចស្រេចកាលណាទើបខ្ញុំនិងលោកគឹ-គឹមស៊ុំជួលរ៉ឺម៉ក ១ វេលាម៉ោង ៤ រសៀលចេញពីផ្សារទន្ទាប់ត្រ-ឡប់មកដល់ផ្សារតាកែវពេលម៉ោង ៧ ល្ងាច បានចូលទៅជួបនឹងព្រះបាទម្ចាស់ចៅហ្វាយខេត្តតាកែវនៅគេហស្ថានរបស់លោក ដើម្បីលាលោកត្រឡប់មកភ្នំពេញវិញផងនិងជំរាបអំពីដំណើរដែលទៅមើលភ្នំបាយ៉ង់ផង

ប៉ុន្តែត្រង់រូបស្វាហនុមាន ១ និងត្រាប់កាំភ្លើងធំ ១ ដែលបានមកអំពីវត្តទាំង ២ នោះគេពុំបានបង្ហាញនឹងដំណឹងឲ្យជ្រាបផងសោះ លុះនឹកឃើញជាខាងក្រោយមានសេចក្តីព្រួយបារម្ភដែរ ប៉ុន្តែដោយមានសង្ឃឹមមាំព្រោះបានសរសេរសុំបុត្រជូនទៅជំរាបលោកចៅហ្វាយស្រុកគិរីវង្សហើយ ។

## អំពីដំណើរមកភ្នំពេញវិញ

ថ្ងៃ ២៥ សេបតេម្ប្រ៊ែពេលម៉ោង ៧ ព្រឹក ខ្ញុំនឹងលោកគី-គឹមស៊ុំ បានចេញដំណើរអំពីតាកែវត្រឡប់ចូលមកភ្នំពេញវិញ ដោយរថយន្តឈ្នួល វេលាម៉ោង ១១ កន្លះព្រឹកក៏បានមកដល់ភ្នំពេញដោយសួស្តី ។

ចំណែកលោកអ៊ុក-សេន នឹងលោកសៅ-សឿនដែលមកជាមួយនឹងទូកនាំព្រះពុទ្ធរូបចេញអំពីអង្គរបុរីពីថ្ងៃ ២១ នោះក៏បានមកដល់ភ្នំពេញនៅវេលាម៉ោង ១២ យប់ក្នុងថ្ងៃ ២៥ នោះដែរ ចាប់ពីត្រឹមពេលម៉ោង ២ រសៀលថ្ងៃ ២៦ រៀងទៅមានការត្រូវដឹកជញ្ជូនយកព្រះពុទ្ធរូបនឹងបល្ល័ង្កជាដើម ឡើងពីទូកដែលចតនៅមុខផ្សារស៊ីញ៉ែកទៅទុកនៅសារមន្ទីររហូតដល់ថ្ងៃ ២៩ ទើបហើយជាស្រេច ដោយអ្នកទោស ៣០ នាក់នឹងពួកគូលីនៅសារមន្ទីរព្រួតគ្នាជួយជញ្ជូន ។

លុះបានរៀបទុកដាក់ក្នុងសារមន្ទីរជាស្រេចហើយ តន្ទឹមកខាងក្រោយគឺនៅវេលាថ្ងៃ ១៨ ឧកត្តូប្រ៊ែ ១៩៤៤ ពេលម៉ោង ៨ ព្រឹក លោកឡឺរ៉េស៊ីដង់ស៊ុប៉េរីយើរ (គោរព) អញ្ជើញទៅទស្សនាការម្តង, ដល់

ថ្ងៃ ២១ ឧកតូប្រ៍ វេលាម៉ោង ៩ ព្រឹក ព្រះករុណា ព្រះបាទសម្តេចព្រះនរោត្តម-សីហនុ ទ្រង់ស្តេចយាងទៅទតម្តង, ដល់ថ្ងៃ ២៣ ឧកតូប្រ៍ វេលាម៉ោង ១១ ព្រឹក លោកគូវ៉េរណ៍រ យ៉េណេរ៉ាល់ ប្រទេសឥណ្ឌូស៊ីន (ហ្សង់-ដឺគូស៍) អញ្ជើញទៅមើលម្តងទៀត មានលោកឡឺរេស៊ីដង់ស៊ុបេរីយើរ និងមន្ត្រីបារាំងជាច្រើនទៅជាមួយផង ។

ឯមហាបុរសទាំង ៣ បានឃើញបុណណវត្ថុទាំងនោះ សឹងសំដែងសេចក្តីសោមនស្សរីករាយជាច្រើន ឯបណ្តាស្ត្រីខ្មែរចិនយួនវិញដែលចូលទៅមើលរាល់ថ្ងៃច្រើនជាអនេកនឹងពណ៌នាពុំបានឡើយ ។

ជាបំផុតនេះខ្ញុំមានចិត្តត្រេកអរដ៏ពន្លឹកឥតឧបមា សរសើរដល់ចេស្តានុភាពនៃព្រះបាទម្ចាស់ថៅហ្វាយខែត្រតាកែវ ហើយនឹកគុណពុំភ្លេចអំពីកិច្ចដែលលោកបានចាត់ការឲ្យខ្ញុំបានសម្រេចដោយស្រួលក្នុងការដឹកនាំបុណណវត្ថុនេះផង សូមអរគុណចំពោះលោក មុី-ឈឹម មេឃុំ អង្គរបុរី ដែលបានជួយខ្នះខ្នែងក្នុងការនេះ ដោយកំឡាំងកាយនឹងវាចារហូតដល់សម្រេច ព្រមទាំងលោកសេហ៊ុំប៊ុស្តិផង សូមអរគុណចំពោះលោកគ្រូយួន នឹងជាតិយួននៅភ្នំដា-ភ្នំទេព ដែលបានជួយខ្វល់ខ្វាយទទួលបដិសណ្ឋារៈស្មោះស្ម័គ្រដោយទឹកដៃជាដើមផង អាយុ វណ្ណៈ សុខៈ ពលៈ សូមឲ្យសម្រេចជាប្រាកដដល់អស់លោក-អ្នកទាំងអស់កុំបីឃ្លាត ។

ភ្នំពេញថ្ងៃ ១៩ ណូវែម្ប្រ៍ ១៩៤៨ យុគបញ្ញាសោភ័ន គាំ-ឌុម

អរិយសច្ច ជាពុទ្ធភាសិត

# លោកគ្រូព្រះអាចារ្យ ប៉ាង-ខាត់ ប្រែនិងរៀបរៀង

(តទៅ)

(ត្រង់នេះទ្រង់សំដែងអសេខធម៌ ១០ ប្រការគឺ សម្មាទិដ្ឋិ: សម្មាសង្កប្ប, សម្មាវាចា, សម្មាកម្មន្ត, សម្មាអាជីវ, សម្មាវាយាម, សម្មាសតិ, សម្មាសមាធិ, សម្មាញាណ, សម្មាវិមុត្តិ) ។

ទសក-អំ- ២៤-២៣១ ១០៧

## អ្នកដែលជាប់នឹងចំណីលោក បួលបិត្តស្តាប់រឿងកាមគុណ មិនបួលបិត្តស្តាប់រឿងស្ងប់ទេ ។

ម្នាលសុនក្ខត្ត:! កាមគុណទាំង ៥ យ៉ាងនោះគឺ រូបដែលបុគ្គលដឹងដោយភ្នែក សំឡេងដែលបុគ្គលដឹងដោយត្រចៀក ក្លិនដែលបុគ្គលដឹងដោយច្រមុះ រសដែលបុគ្គលដឹងដោយអណ្តាត ផោដ្ឋព្វ:ដែលបុគ្គលដឹងដោយកាយ ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត មានសភាពគួរស្រឡាញ់ ប្រកបដោយកាម រំភើបនៃការត្រេកអរ ។ ម្នាលសុនក្ខត្ត:! នេះឯងឈ្មោះថា កាមគុណ ៥ ប្រការ ។

ម្នាលសុនក្ខត្ត:! ហេតុនេះជាឋាន: មានទំនងឲ្យអ្នកផងគេថាបាន មានបុរិសបុគ្គលពួកខ្លះក្នុងលោកនេះ មានអធ្យាស្រ័យទន់ទៅរកចំណី

លោក (គឺកាមគុណ ៥ យ៉ាង) ពាក្យសំដីបុរសបុគ្គលដែលមានអធ្យា-ស្រ័យទន់ទៅរកចំណីលោក តែងតាំងនិយាយទៀងតែងប្រមៀលសេចក្តីទៅរកកាមគុណ ពេញចិត្តត្រិះរិះនូវពិចារណារឿយៗ ។ រកហេតុដែលអនុលោមទៅតាមកាមគុណ ចូលចិត្តសេពគប់នូវបុរសកាមគុណ គោរពពាក់ពាន់បុរសកាមគុណ ។ រីឯពាក្យសំដីដែលគេនិយាយប្រកបដោយសមាបត្តិដែលញាប់ញ័រ (ដោយកាមគុណ) បុរសបុគ្គល (ដែលជាប់គន្លងចំណីលោក) នោះ មិនចូលចិត្តស្តាប់ មិនផ្ទៀងត្រចៀកស្តាប់ មិនតាំងចិត្តដើម្បីដឹងស្តាប់ មិនគប់រកបុគ្គលនោះផង មិនគោរពបុគ្គលនោះផង ៗ ម្នាលសុនក្ខត្តៈ! ដូចជាបុរសម្នាក់ មានដំណើរចេញអំពីស្រុកឬនិគមរបស់ខ្លួនដែលជាទីធ្លាប់នៅយូរយារហើយ, កាលបើបានឃើញបុរសណាម្នាក់ដែលគេទើបនឹងចេញអំពីស្រុកឬនិគមរបស់ខ្លួននោះ តែងសាកសួរដំណឹងអំពីស្រុកឬនិគមរបស់ខ្លួន អំពីសេចក្តីក្សេមក្សាន្ត អំពីមានភិក្ខា-ហារដ៏បរិបូណ៌ ឬពុំនោះអំពីមានជម្ងឺដ៏កាត់, ឯបុរសនោះក៏ប្រាប់តបវិញ (តាមដំណើរ) ។ ម្នាលសុនក្ខត្តៈ! អ្នកយល់ចិត្តសេចក្តីនេះជាដូចម្តេច? ចុះបុរសអ្នកដំណើរនោះស្តាប់ពាក្យបុរសនោះ (អ្នកទើបមកថ្មី) ដោយប្រៀបតាំងចិត្តស្តាប់ ដើម្បីដឹង ពេញចិត្តនឹងបុរសនោះផង គោរពបុគ្គលនោះផង ឬទេ? ។

## សត្វដែលជាប់នៃកាមគុណ តែងវង្វេងឈ្លក់ក្នុងកាមថាជាសុខ

ម្នាលមាគណ្ឌិយៈ! អ្នកសំគាល់សេចក្ដីនោះដូចម្ដេច? ភ្លើងនោះមានសម្ផស្សជាទុក្ខក្ដៅក្រហាយខ្លាំង ពេលពលខ្លាំង តែក្នុងកាលឥឡូវនេះទេឬ ឬកាលពីអតីតដូច្នេះដែរ? បពិត្រព្រះគោតមដ៏ចំរើន! ក្នុងកាលឥឡូវនេះក្ដី ភ្លើងនោះក៏មានសម្ផស្សជាទុក្ខ ក្ដៅក្រហាយខ្លាំង ពេលពលខ្លាំង កាលពីអតីតសោតក៏ដូចគ្នាដែរ, រីបុរសឃ្លង់ ដែលមានខ្លួនដំបៅ មានខ្លួនហើមស្អុល ដង្កូវទាំងឡាយកំពុងជញ្ជក់ស៊ី, ខ្វារមុខដំបៅដោយក្រចកទាំងឡាយមានឥន្ទ្រិយស្គមគ្រាំគ ក៏មានសេចក្ដីសំគាល់ខុសយកភ្លើងដែលមានសម្ផស្សក្ដៅជាទុក្ខ (នោះ) ថាជាសុខស្រួលវិញ ។

ម្នាលមាគណ្ឌិយៈ! យ៉ាងហ្នឹងមែនហើយ ក្នុងអតីតកាលយូរអង្វែងមកហើយ កាមទាំងឡាយក៏មានសម្ផស្សជាទុក្ខ ក្ដៅក្រហាយខ្លាំងពេលពលខ្លាំង, ក្នុងអនាគតដែលមិនទាន់មានមក ក៏ក្ដៅដូចគ្នា, ក្នុងកាលបច្ចុប្បន្នឥឡូវនេះសោតក៏ដូចគ្នាដែរ. (មិនមែនភ្លើងក្ដៅពេលពលខុសគ្នាទេ) ម្នាលមាគណ្ឌិយៈ! សត្វទាំងនេះ ដែលមិនទាន់ប្រាសចាកតំរេកក្នុងកាមទាំងឡាយ ដែលកាមតណ្ហាកំពុងទំពាស៊ី ពេលពល់ដោយសេចក្ដីក្ដៅក្រហាយព្រោះកាម មានឥន្ទ្រិយដែលគាមបៀតបៀនហើយ ក៏នៅតែមានសេចក្ដីសំគាល់ខុសក្នុងកាមទាំងឡាយ ដែលមានសម្ផស្សក្ដៅជាទុក្ខ សំគាល់ថាជាសុខស្រួលវិញ ។

ម-ម- មាគណ្ឌិយសូត្រ ២៤ - ៣៦ - ៤៥

លុះកាលណាប្រាជ្ញាកើតឡើង ទើបសត្វលោកស្គាល់សេចក្ដីសុខពិត ។

ម្នាលមាគណ្ឌិយៈ! ប្រៀបដូចបុរសខ្វាក់អំពីកំណើត មិនដែលបានឃើញរូបពណ៌ខ្មៅនិងស ខៀវ លឿង ក្រហម ហង្សបាទ មិនដែលឃើញទីរាបស្មើនិងមិនស្មើ មិនដែលឃើញរូបផ្កាយ ព្រះចន្ទ ព្រះអាទិត្យ បុរសខ្វាក់ពីកំណើតឮបុរសមានភ្នែកភ្លឺនិយាយថា: "អ្នកដ៏ចំរើន! យីអើ សំពត់សស្អាតបរិសុទ្ធ ឥតមានមន្ទិលអ្វីទេ ។ បុរសខ្វាក់អំពីកំណើតនោះ ក៏ដើរស្វែងរកសំពត់ស ។ មានបុរសម្នាក់យកសំពត់ក្រាស់ដែលធ្វើដោយរោមចៀមទៅ. ជ្រលក់ដោយម្រែងក្អែងលាយប្រេងមកបញ្ឆោតបុរសនោះថា: "នែបុរសដ៏ចំរើន! នេះសំពត់សល្អស្អាត ឥតមានមន្ទិលសៅហ្មងអ្វីទេ" ។ បុរសខ្វាក់ភ្នែកអំពីកំណើតទទួលយកសំពត់នោះយកទៅដណ្ដប់ ហើយនិយាយបែបញញឹមថា: "យីអើ សំពត់សល្អស្អាតបរិសុទ្ធ ឥតមានមន្ទិលអ្វី" ។ មិត្រអាមាត្យញាតិលោហិត របស់បុរសខ្វាក់អំពីកំណើតនោះ ឲ្យពេទ្យវះថែរក្សា ពេទ្យអ្នកវះថែរក្សាក៏បានផ្សំថ្នាំឲ្យ គឺថ្នាំធ្វើឲ្យក្អួត ថ្នាំបញ្ចុះ ថ្នាំបន្តក់ ថ្នាំលាង ថ្នាំហិត បុរសខ្វាក់អំពីកំណើតបានអាស្រ័យថ្នាំនេះហើយ ក៏បានញ៉ាំងចក្ខុឲ្យកើតឡើងឲ្យភ្លឺឡើង បុរសនោះក៏មិនពេញចិត្តនឹងសំពត់សាច់ក្រាស់ ដែលធ្វើ

ដោយកេមរបៀមទៅ ដែលកើតដោយមែនកើតណាយប្រែង ហើយ
លះបង់បោលក្នុងពេលដែលបានកែកក្តីឡើងវិញ ហើយទុកបុរសដែល
បញ្ឆោតខ្លួននោះថាមិនមែនជាមិត្រផង ថាជាសត្រូវផង ឬក៏នោះ
ក៏យល់ថាត្រូវសម្លាប់បោលក៏សិនតែបាន ដោយគិតឃើញថាៈ "ខបុរស
នេះ យកសំពត់មានសាច់ក្រាស់ដែលធ្វើដោយកេមរបៀមទៅ ដែលកើត
ដោយមែនកើតណាយប្រែង មកបោកបញ្ឆោតប្រលោមអញថាជា
របស់សបរិសុទ្ធអស់កាលយូរហើយ" (សេចក្តីនេះមានឧបមាយ៉ាង
ណាមិញ) ម្នាលមាគណ្ឌិយៈ តថាគតគួរទីនសំដែងធម៌ដល់អ្នកថាៈ
'នេះជាសេចក្តីមិនមានរោគ នេះជាព្រះនិព្វាន' ក៏មានឧបមេយ្យដូច្នោះ
ដែរ ៗ អ្នកគប្បីដឹងសេចក្តីមិនមានរោគ ឃើញនូវព្រះនិព្វាន; ឧទ្ទកគ
ឯណាក្នុងបាទក្ខខេត្តាំង ៤ ឧទ្ទកគនោះនៅរះបង់បោលក្នុងពេល
ដែលកើតចក្ខុឡើង មួយទៀត អ្នកត្រូវត្រិះរិះយ៉ាងនេះថាៈ "ខញុំ ចិត្ត
នេះ បោកបញ្ឆោតប្រលោមអាត្មាអញអស់កាលយូរមកហើយ បាន
ជាអាត្មាអញកាលប្រកាន់ ក៏ប្រកាន់ចំពោះរូបហ្នឹងឯង ចំពោះវេទនា
ហ្នឹងឯង ចំពោះសញ្ញាហ្នឹងឯង ចំពោះសង្ខារហ្នឹងឯង ចំពោះវិញ្ញាណ
ហ្នឹងឯង ភពដែលកើតឡើងដល់អាត្មាអញនោះ ព្រោះមានឧបាទាន
ជាបច្ច័យ ជាតិកើតឡើង ព្រោះមានភពជាបច្ច័យ ជរាមរណៈ សេចក្តី

ខ្សឹកខ្សួល ទុក្ខ ទោមនស្ស និងសេចក្ដីខ្វោចផ្សាចិត្តកើតឡើង ព្រោះមានជាតិជាបច្ច័យ ការដែលកើតឡើងនៃកងទុក្ខទាំងអស់នេះ រមែងកើតឡើងដោយការប្រកាន់យ៉ាងនេះឯង ។

ខ-ម-អាគណ្ឌិយសូត្រ ២៤-៨៥-៥០

បទទី ២

## ជីវិតមនុស្ស និងចតុរារិយសច្ច

## មនុស្សទាំងឡាយច្រើនគ្នា ប្រកាន់យកទីពឹងខុស

មនុស្សទាំងឡាយច្រើនគ្នាណាស់ ដែលមានភ័យគំរាមកំញើញហើយ តែងរត់ទៅជ្រកកទីពឹងភ្នំខ្លះ ព្រៃព្រឹក្សាខ្លះ សួនច្បារខ្លះ រុក្ខចេតិយខ្លះ ការរត់ទៅជ្រកកទីពឹងទាំងអស់នេះ មិនមែនជាទីពឹងដ៏ក្សេមក្សាន្តទេ មិនមែនជាទីពឹងដ៏ឧត្ដមទេ, មនុស្សទាំងឡាយ ដែលអាស្រ័យទីពឹងទាំងនេះ មិនរួចស្រឡះចាកទុក្ខទាំងពួងបានឡើយ ។

អ្នកឯណាមួយ យកព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ជាទីពឹងពំនាក់ហើយ ឃើញច្បាស់នូវអរិយសច្ចទាំងឡាយ ៤ ប្រការ ដោយប្រាជ្ញាដ៏មុះមុត គឺ ឃើញទុក្ខ ឃើញហេតុប្រជុំកើតឡើងនៃទុក្ខ ឃើញការកន្លងបង់នូវទុក្ខ ឃើញមគ្គប្រកបដោយអង្គ ៨ ប្រការដ៏ប្រសើរ ដែលជាធម៌នាំឲ្យរម្ងាប់បង់នៃទុក្ខ ទីពឹងនេះឯងជាទីពឹងដ៏ក្សេមក្សាន្តជាទី

ពីនជំទុក្ខទុក្ខ, រីអ្នកនោះឯង ដែលបានអាស្រ័យនូវទីពីងនេះហើយ តែងរួចស្រឡះចាកទុក្ខទាំងពួងបានហោង ។

ពន្ធបទ៖ ១-២៥-៤០-២៤.

## អ្នកដែលមិនដឹងអរិយសច្ច ឈ្មោះថាកសាងអន្លង់នៃសេចក្ដីទុក្ខឲ្យខ្លួនតទៅ ។

ម្នាលភិក្ខុទាំងឡាយ! បុគ្គលឯណាមួយ ជាសមណៈឬជាព្រាហ្មណ៍ ដែលមិនដឹងច្បាស់តាមសេចក្ដីពិតថា: “នេះទុក្ខ នេះហេតុប្រជុំកើតឡើងនៃទុក្ខ នេះធម៌ជាគ្រឿងរលត់ទុក្ខ នេះសេចក្ដីប្រតិបត្តិជាដំណើរទៅកាន់ទីរលត់ទុក្ខ ដូច្នេះ” បុគ្គលទាំងឡាយនោះ តែងអភិរម្យត្រេកអរក្នុងសង្ខារទាំងឡាយ ដែលតាក់តែងប្រព្រឹត្តទៅដើម្បី ជាតិ ជរា ព្យាធិ មរណៈ សេចក្ដីសោក យំខ្សឹកខ្សួល ទុក្ខកាយ ទុក្ខចិត្ត និងចង្អៀតចង្អល់ចិត្ត ។ បុគ្គលទាំងឡាយនោះឯង ដែលត្រេកអរអភិរម្យក្នុងសង្ខារទាំងឡាយ ដែលតាក់តែងមានការតាក់តែងជាតិជាដើមបែបនោះៗ ហើយ ឈ្មោះថាកសាងនូវសង្ខារទាំងឡាយជាគ្រឿងតាក់តែង ដែលប្រព្រឹត្តទៅដើម្បីជាតិ ជរា ព្យាធិ មរណៈជាដើមនោះៗ លុះបុគ្គលទាំងឡាយ កសាងនូវសង្ខារទាំងឡាយមានជាតិជាដើមបែបនោះៗ ហើយក៏ធ្លាក់ក្នុងទៅក្នុងអន្លង់នៃជាតិ ជរា ព្យាធិ មរណៈ សេចក្ដីសោក យំខ្សឹកខ្សួល សេចក្ដីទុក្ខកាយ ទុក្ខចិត្ត និងចង្អៀតចង្អល់ចិត្ត នោះឯង ។ ពាថាគតពោលទុក

ខ្សឹកខ្សួល ទុក្ខ ទោមនស្ស និងសេចក្ដីខ្ទោបផ្សាចិត្តកើតឡើង ព្រោះ មានជាតិជាបច្ច័យ ការដែលកើតឡើងនៃកងទុក្ខទាំងអស់នេះ រមែង កើតឡើងដោយការប្រកាន់យ៉ាងនេះឯង ។

ម.ម-មាគណ្ឌិយសូត្រ ៦៤-៨៥-៩០

បទទី ២

## ជីវិតមនុស្ស និងចតុរារិយសច្ច

## មនុស្សទាំងឡាយច្រើនគ្នា ប្រកាន់យកទីពឹងខុស

មនុស្សទាំងឡាយច្រើនគ្នាណាស់ ដែលមានភ័យគំរាមកំហែង ហើយ តែងរត់ទៅរកទីពឹងភ្នំក្រំថ្មខ្លះ ព្រៃព្រឹក្សាខ្លះ សួនច្បារខ្លះ រុក្ខចេតិយខ្លះ ការរត់ទៅរកទីពឹងទាំងអស់នេះ មិនមែនជាទីពឹងដ៏ក្សេមក្សាន្តទេ មិនមែនជាទីពឹងដ៏ឧត្តុង្គឧត្ដមទេ, មនុស្សទាំងឡាយ ដែល អាស្រ័យទីពឹងទាំងនេះ មិនរួចស្រឡះពាកទុក្ខទាំងពួងបានឡើយ ។

រីអ្នកឯណាមួយ យកព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ជាទីពឹង ពំនាក់ហើយ ឃើញច្បាស់នូវអរិយសច្ចទាំងឡាយ ៤ ប្រការ ដោយ ប្រាជ្ញាដ៏មុះមុត គឺ ឃើញទុក្ខ ឃើញហេតុប្រជុំកើតឡើងនៃទុក្ខ ឃើញ ការរលត់បង់នូវទុក្ខ ឃើញមគ្គប្រកបដោយអង្គ ៨ ប្រការដ៏ប្រសើរ ដែល ជាធម៌នាំឲ្យរម្ងាប់បង់នៃទុក្ខ ទីពឹងនេះឯងជាទីពឹងដ៏ក្សេមក្សាន្តជាទី

ពីងដំទត្តទុត្តម, អ្នកនោះឯង ដែលបានអាស្រ័យនូវទីពឹងនេះហើយ តែងរួចស្រឡះចាកទុក្ខទាំងពួងបានហោង ។

ធម្មបទ ។ ១ - ២៥ - ៤០ - ២៤.

## អ្នកដែលមិនដឹងអរិយសច្ច ឈ្មោះថាកសាងអន្លង់នៃសេចក្ដីទុក្ខឲ្យខ្លួនតទៅ ។

ម្នាលភិក្ខុទាំងឡាយ! បុគ្គលឯណាមួយៈជាសមណៈឬជាព្រាហ្មណ៍ ដែលមិនដឹងច្បាស់តាមសេចក្ដីពិតថា: "នេះទុក្ខ នេះហេតុប្រជុំកើតឡើងនៃទុក្ខ នេះធម៌ជាគ្រឿងរំលត់ទុក្ខ នេះសេចក្ដីប្រតិបត្តិជាដំណើរទៅកាន់ទីរំលត់ទុក្ខ ដូច្នេះ" បុគ្គលទាំងឡាយនោះ តែងអភិរម្យត្រេកអរក្នុងសង្ខារទាំងឡាយ ដែលតាក់តែងប្រព្រឹត្តទៅដើម្បី ជាតិ ជរា ព្យាធិ មរណៈ សេចក្ដីសោក យំខ្សឹកខ្សួល ទុក្ខកាយ ទុក្ខចិត្ត និងចង្អៀតចង្អល់ចិត្ត ។ បុគ្គលទាំងឡាយនោះឯង ដែលត្រេកអរអភិរម្យក្នុងសង្ខារទាំងឡាយ ដែលតាក់តែងមានការតាក់តែងជាតិជាដើមបែបនោះៗ ហើយ ឈ្មោះថាកសាងនូវសង្ខារទាំងឡាយជាគ្រឿងតាក់តែង ដែលប្រព្រឹត្តទៅដើម្បី ជាតិ ជរា ព្យាធិ មរណៈជាដើមនោះៗ លុះបុគ្គលទាំងឡាយ កសាងនូវសង្ខារទាំងឡាយមានជាតិជាដើមបែបនោះៗ ហើយក៏ធ្លាក់ក្នុងទៅក្នុងអន្លង់នៃជាតិ ជរា ព្យាធិ មរណៈ សេចក្ដីសោក យំខ្សឹកខ្សួល សេចក្ដីទុក្ខកាយ ទុក្ខចិត្ត និងចង្អៀតចង្អល់ចិត្ត នោះឯង ។ តថាគតពោលទុក

ថា: "បុគ្គលទាំងឡាយនោះ មិនរួចស្រឡះអំពីជាតិ ជរា ព្យាធិ មរណៈ យំខ្សឹកខ្សួល សោចក្តីទុក្ខកាយ ទុក្ខចិត្ត និងចង្អៀតចង្អល់ចិត្តនោះទេ ឈ្មោះថាមិនរួចស្រឡះអំពីទុក្ខទុះទេ" ។

អ្នកដែលដឹងច្បាស់នូវអរិយសច្ច ឈ្មោះថាមិនកសាងអន្លង់ទុក្ខឲ្យខ្លួនទេ ។

រីឯបុគ្គលឯណាមួយជាសមណៈឬជាព្រាហ្មណ៍ ដែលដឹងច្បាស់តាមសេចក្តីពិតថា: "នេះទុក្ខ នេះហេតុប្រជុំកើតឡើងនៃទុក្ខ នេះធម៌ជាគ្រឿងរំលត់ទុក្ខ នេះសេចក្តីប្រតិបត្តិជាដំណើរទៅកាន់ទីរំលត់ទុក្ខ ដូច្នេះ" បុគ្គលទាំងឡាយនោះ មិនអភិរម្យត្រេកអរក្នុងសង្ខារទាំងឡាយជាគ្រឿងតាក់តែង ដែលប្រព្រឹត្តទៅដើម្បី ជាតិ ជរា ព្យាធិ មរណៈ សេចក្តីសោកយំ ខ្សឹកខ្សួល ទុក្ខកាយ ទុក្ខចិត្ត និងចង្អៀតចង្អល់ចិត្តទុះទេ ។ បុគ្គលទាំងឡាយនោះ ដែលមិនអភិរម្យត្រេកអរក្នុងសង្ខារទាំងឡាយជាគ្រឿងតាក់តែងមានការតាក់តែងជាតិជាដើមថែបនោះៗ ហើយ ឈ្មោះថាមិនកសាងនូវសង្ខារទាំងឡាយជាគ្រឿងតាក់តែងដែលប្រព្រឹត្តទៅ ដើម្បីជាតិ ជរា ព្យាធិ មរណៈ ជាដើមនោះៗ, លុះបុគ្គលទាំងឡាយនោះមិនកសាងសង្ខារទាំងឡាយជាគ្រឿងតាក់តែង មានការតាក់តែងជាតិជាដើមនោះៗ ហើយ ក៏មិនធ្លាក់ក្នុងចុះទៅក្នុងអន្លង់គឺ ជាតិ ជរា ព្យាធិ មរណៈ សេចក្តីសោកៈ យំខ្សឹកខ្សួល ទុក្ខកាយ ទុក្ខចិត្ត និងចង្អៀត

បន្ទល់ចិត្តទៀតទេ ។ តថាគតពោលទុក្ខថា: "បុគ្គលទាំងឡាយណានោះរួចស្រឡះអំពីជាតិ ជរា ព្យាធិ មរណៈ សេចក្ដីសោក យំខ្សឹកខ្សួល ទុក្ខកាយ ទុក្ខចិត្ត និងចង្អៀតចង្អល់ចិត្ត ឈ្មោះថារួចស្រឡះអំពីសេចក្ដីទុក្ខបាន" ។ ម្នាលភិក្ខុទាំងឡាយ! ព្រោះហេតុនោះ អ្នកទាំងឡាយគប្បីធ្វើសេចក្ដីព្យាយាម ដើម្បីឲ្យដឹងច្បាស់ថា: "នេះទុក្ខ នេះហេតុប្រជុំកើតឡើងនៃទុក្ខ នេះធម៌ជាគ្រឿងរំលត់បង់នូវទុក្ខ នេះសេចក្ដីប្រតិបត្តិជាដំណើរទៅកាន់ទីរំលត់ទុក្ខដូច្នេះ" ។

មហាវារៈ សំ. ១៩-៥៦០-១៧២៨

## គ្រាន់តែផ្ដើមដឹងច្បាស់អរិយសច្ចប៉ុណ្ណោះ សេចក្ដីទុក្ខដែលអស់ទៅច្រើនជាងដែលសល់ ។

ម្នាលភិក្ខុទាំងឡាយ! អ្នកទាំងឡាយសំគាល់សេចក្ដីនេះថាដូចម្ដេច? ដីឯណាច្រើនជាងឯណា? គឺដីបន្តិចដែលដាក់នៅចុងក្រចកតថាគត និងមហាប្រថពីនេះ? បពិត្រព្រះអង្គដ៏ចំរើន! មហាប្រថពីច្រើនសែនច្រើន ដីបន្តិចដែលទ្រង់ដាក់នៅចុងក្រចកព្រះហស្តនេះជារបស់តិចណាស់ ស្មើរតែមិនគួរពោល និងមិនគួរយកមកផ្ទឹម មិនបានមួយចំណិតនិងមិនគួរប្រៀបផ្ទឹមនឹងមហាប្រថពីឡើយ ។ ម្នាលភិក្ខុទាំងឡាយ! ខាងឧបមាយ៉ាងណា ឧបមេយ្យដូចជា សេចក្ដីទុក្ខរបស់បុគ្គលជាអរិយសាវក[1]

១ សោតាបន្នបុគ្គលជាន់សត្តក្ខត្តុំបរមជាអរិយបុគ្គលជាន់ទាបក្នុងពួកសោតាបន្នបុគ្គល ។

លោកបរិបូណ៌ដោយកិរិយាឃើញ លោកដឹងច្បាស់លាស់ហើយ, ដែលអស់ទៅហើយ ទឹកសាបសូន្យទៅហើយនុ៎ះ ច្រើនសែនច្រើន ឯទុក្ខដែលសល់នៅ ជាបរិត្តបណាស់ ស្មើតែមិនគួរពាប់មិនគួរយកមកផ្ទឹម មិនបានមួយចំណិត ទឹកមិនគួរប្រៀបផ្ទឹមទឹកទុក្ខដែលអស់ទៅសាបសូន្យទៅឡើយ ។ ព្រះអរិយបុគ្គលនោះ លោកត្រាស់ដឹងតាមពិតថា: "នេះទុក្ខ នេះហេតុប្រជុំកើតឡើងនៃទុក្ខ នេះធម៌ជាគ្រឿងរំលត់ទុក្ខ នេះសេចក្ដីប្រតិបត្តិជាដំណើរទៅកាន់ទីរំលត់ទុក្ខ" ។ ម្នាលភិក្ខុទាំងឡាយ! ព្រោះហេតុនោះ អ្នកទាំងឡាយគប្បីធ្វើព្យាយាមដើម្បីឲ្យដឹងច្បាស់ថា: "នេះទុក្ខ នេះហេតុប្រជុំកើតឡើងនៃទុក្ខ នេះធម៌ជាគ្រឿងរំលត់ទុក្ខ នេះសេចក្ដីប្រតិបត្តិជាដំណើរទៅកាន់ទីរំលត់ទុក្ខដូច្នេះចុះ" ។

មហាវារៈ សំ. ១៩ - ៥៣២ - ១៧៤៣.

## អ្នកដែលមិនដឹងច្បាស់នូវអរិយសច្ច ឈ្មោះថាធ្លាក់ទងជិតគំទុក្ខ

ម្នាលភិក្ខុ! បុគ្គលឯណានីមួយ ជាសមណៈឬជាព្រាហ្មណ៍ មិនដឹងច្បាស់តាមពិតថា: "នេះទុក្ខ នេះហេតុប្រជុំកើតឡើងនៃទុក្ខ នេះធម៌ជាគ្រឿងរំលត់ទុក្ខ នេះសេចក្ដីប្រតិបត្តិជាដំណើរទៅកាន់ទីរំលត់ទុក្ខ ។

(មានត)

ឯកភាគនៃមិលិន្ទបញ្ហា

## ហ្វូងនិពន្ធមន្ត្រី ញ៉ុក-ថែម រួបរួមប្រែ

(តមក)

ពួកមានអង្គ ៥

## អង្គ ៥ របស់មាន់

១ – បើព្រឹកនៅយប់ងងឹត ក៏ពួនក្នុងសំបុកឬទ្រនំ មិនទាន់ចុះទៅស្វែងរកអាហារទេ ។

២ – លុះព្រឹកភ្លឺហើយ ទើបចុះដើរដើររកអាហារ ។

៣ – នឹងចឹកស៊ីអាហារ តែងយកជើងកកាយដីទើបចឹកស៊ី ។

៤ – ក្នុងវេលាថ្ងៃ សូម្បីមានភ្នែកភ្លឺមើលឃើញច្បាស់ ដល់វេលាយប់បែរជាស្រអាំងងងឹតដូចភ្នែកខ្វាក់ ។

៥ – ទុកជាគេយកដុំដីបោលឬបោលទង់កំណាត់ឈើឬដេញមិនឲ្យមកចូលទ្រនំ ក៏មិនព្រមលះបង់ចោលទ្រនំរបស់ខ្លួនឡើយ ។

ប្រៀបដូចអ្នកប្រតិបត្តិប្រកបដោយអង្គសម្បត្តិ ៥ ប្រការ គឺ :

១ – កាលជិតព្រឹកនៅយប់ងងឹត ក៏បោសប្រាសសំអាតទីបរិវេណ រៀបចាត់តាំងគ្រឿងប្រើប្រាស់ចាត់ឲ្យមានរបៀបរៀបរយល្អ ងូតទឹកជម្រះកាយឲ្យស្អាតហ្មត់ចត់ហើយ ក៏ចូលក្រាបសំពះបូជនីយវត្ថុ ជាកិច្ចវត្តប្រចាំខ្លួន ។

២ – លុះព្រឹកភ្លឺឡើង ក៏ធ្វើការណ៍យកកិច្ចទានការដាក់កម្មជាដើមតាមមុខក្រសួង តាមភេទរបស់ខ្លួន ។

៣ – ពិចារណាជាមុនហើយទើបបរិភោគអាហារភោជន ៖

៤ – ក្រែកមិនខ្ទាក់ ក៏ធ្វើដូចជាខ្ទាក់ គឺទុកជានៅក្នុងទីណានីមួយ ក៏តាំងចិត្តស្រើបស្រើយ កុំឲ្យត្រេកអរក្នុងអារម្មណ៍ដែលគួរប្រាថ្នា ជាទីតាំងនៃតម្រេក កុំឲ្យអន់ចិត្តក្នុងអារម្មណ៍មិនជាទីប្រាថ្នា ដែលជាទីតាំងនៃកំហឹងនឹងការស្អប់ខ្ពើម ។

៥ – ទុកជាធ្វើអ្វីៗក៏ដោយ ក៏មិនព្រមលះបង់យោនិសោមនសិការៈ ដូចជាយានមិនព្រមលះបង់ចំនួនរបស់ខ្លួន ។

## អង្គ ៥ របស់អណ្តើក

១ – ត្រេចនៅក្នុងទឹក ឬស្រែយនៅក្នុងទឹក ។

២ – មុជនៅក្នុងទឹក កាលងើបក្បាលមកលើទឹកបានឃើញអ្វីៗ ក៏ត្រឡប់មុជទៅវិញ មិនឲ្យនរណាមើលឃើញខ្លួនឡើយ ។

៣ – លុះងើបពីទឹកមកហើយ មិនឃើញមានអ្វី គឺហាលសំដិលកាយនៅក្នុងផ្ដះទ្រូប ។

៤ – ជីកដីមុជខ្លួនពួននៅក្នុងទីស្ងាត់ ។

៥ – កាលត្រាច់ដើរទៅ បើបានឃើញមនុស្សឬសត្វអ្វីៗ មួយឬ

បានឮសំឡេងអ្វី  ក៏ពង្រួញអវយវៈទាំង ៥ គឺជើង ៤ ក្បាល ១ ចូលទៅក្នុងស្នូករបស់ខ្លួន  ប្រយ័ត្នខ្លួនស្ងៀមនៅ ។

ប្រៀបដូចអ្នកប្រតិបត្តិប្រកបដោយឥន្ទ្រិយសម្បត្តិ ៥ ប្រការគឺ:

១ — ផ្សាយមេត្តាចិត្តដ៏ត្រជាក់  តាំងចិត្តឲ្យជាប្រយោជន៍ដល់សត្វលោកទូទៅ  មិនមានព្យាបាទការចងពៀរ  តាំងចិត្តភ្ជាប់ខ្លួននៅក្នុងព្រហ្មវិហារ ។

២ — កាលកិលេសកើតឡើង  គឺទ្រាំអត់សង្កត់សង្កិនឲ្យលិចចុះទៅក្នុងអារម្មណ៍ដូចជាវៀចតាប់ឃាត់អារម្មណ៍មិនឲ្យខ្ចាត់  មិនឲ្យពួកកិលេសហៀរចូលមកគ្របសង្កត់សន្តានចិត្តបាន ។

៣ — នាំចិត្តចេញចាកវិស័យបាប  ដេក, ដើរ, ឈរ, អង្គុយ, ហើយខំប្រឹងប្រកបកុសលសម្បជាន ។

៤ — លះបង់លាភសក្ការៈ និងពាក្យពោលសរសើរ ហើយគប្បីចូលទៅនៅសម្ងំក្នុងទីស្ងប់ស្ងាត់ ។

៥ — កាលបើទ្វារទាំង ៦ ធ្លាក់ទៅនៅក្នុងកាមារម្មណ៍  ដែលជាទីតាំងនៃតម្រេកត្រេកត្រអាល  ក៏បិទទ្វារតែឥន្ទ្រិយសំវរៈ  សង្កត់ចិត្តឲ្យមានសំវរៈ  ដោយមានសតិសម្បជញ្ញៈអង្គុយចំរើនកុសលធម៌ ។

(មានត)